# LA VIE DES ANIMAUX

## on compte les écureuils

Les zoologistes anglais voulaient connaitre la répartition exacte des écureuils qui vivent encore dans les îles britanniques. Pour ce faire le World Wild life Fund a mobilisé les écoliers. Les enfants ont envoyé des milliers de rapports signalant en des points déterminés la présence d'écureuils appartenant à l'une des deux espèces, la grise et la rousse. Et les Anglais ont maintenant leur carte des écureuils .

## le vison et le poisson

Le vison qui s'échappe occasionnellement d'élevages est à l'état naturel un animal semi aquatique qui nage fort bien et sait se nourrir de poissons. Des pêcheurs britanniques ont surpris des visons qui après avoir choisi la liberté, dévalisaient sans scrupule les paniers des pêcheurs à la tombée de la nuit.

## chèvre à conserver

Les services espagnols des eaux et forêts s'efforcent de conserver une espèce voie de disparition la «capra hispanica» magnifique bouquetin qui n'existe plus qu'en Espagne et dont le nombre atteint aujourd'hui à peine 10.000; la chasse en est rigoureusement interdite.

## le papillon

Le papillon, fleur sans tige qui voltige que l'on cueille en un roseau, dans la nature infinie. Harmonie entre la plante et l'oiseau.

G. de NERVAL

## à la recherche des animaux perdus

Des anthropologues et des préhistoriens américains ont découvert, à 140 km de Madrid, ce qu'ils croient être un lieu d'abattage ou un cimetière d'animaux géants de la préhistoire.

Ils ont déjà déterré une cinquantaine de squelettes d'éléphant qui atteignait alors une hauteur de 5m.

## la huppe et l'été

Il parait que l'été prochain sera très beau, si l'on en croit les signes annonciateurs comme l'apparition de ce charmant oiseau qui s'appelle la huppe. La huppe signifie un été chaud, et l'on a vu trois de ces oiseaux à l'île de Wight, en six jours.

## on a toujours besoin d'un plus petit que soi

Les battements du coeur d'un poisson rouge ont fourni la décharge électrique pour faire démarrer un buldozer géant, à Dallas, Texas. Cette expérience extraordinaire a eu lieu lors de la pose de la première pierre d'une usine où seront construits des instruments de haute précision pour les opérations du cerveau et des yeux.

## trop gourmand

Seekou, le jeune hippopotame d'un an de l'aquarium de New York est mort d'indigestion. Dans son estomac, on a trouvé une quantité d'objets jetés par les visiteurs: un collier de pertes (fausses). un portefeuille vide, sept objets en plastique, deux ceintures, des paquets

(vides) de bonbons et de cigarettes, etc . . . Le directeur a publié cet avis: « Ne tuez pas nos bébés animaux. Jetons-nous du poisson dans vos voitures d'enfants ? »

## des souris et des hommes

Il existe outre- Manche un «club des Amis des Souris» qui organise chaque année plusieurs expositions de «souris de race». Certains de ces rongeurs atteignent des prix insoupçonnés. Le club vient de demander aux chemins de fer britanniques abaissement du tarif appliqué au transport des souris qui pour les courtes distances est plus élevé que pour les hommes.

## comme son maître

Le chien, l'animal le plus attaché à l'homme est aussi celui qui souffre le plus de dépressions nerveuses. Elles sont le plus souvent causées par l'indifférence, l'incompréhension et la cruauté de ses maîtres. C'est un des premiers enseignements des spécialistes de cette science nouvelle, la psychiatrie animale.

## 134 espèces d'oiseaux à Londres

Les ornithologues ont reconnu et identifié 134 espèces d'oiseaux qui nichent et vivent dans le centre de Londres, grâce aux grands parcs de la capitale. En outre, ils ont identifié une soixantaine d'oiseaux migrateurs.

Outre ces hôtes de la capitale, on compte des espèces plus rares dans les grands espaces verts qui entourent. Londres: beaucoup de canards sauvages sur les bords la Tamise, le bruant, la linotte, l'alouette, le faucon, et même la perdrix et les faisans dans le parc de Hampton Court, à Byshy Park, et dans le parc de Richmond, sans parler des pigeons qui sont partout.

## Thermomètre pour dauphins

La température du corps d'un dauphin a été enregistrée par R. Stuart Mackay, biophysicien de l'Université du Californie. Un minuscule émetteur de radio a été inséré dans un pisson mort que l'on a fait avaler à un dauphin femelle nageant dans un aquarium de recherche plein d'eau de mer, à Point Mugu (Californie). Les températures ont été mesurées pendant que le dauphin dormait mangeait, jouait et se livrait à toutes ses activités normales jusqu'au moment où l'animal a éliminé l'appareil, qui émettait encore 17 heures après avoir été avalé par le dauphin.

## trompe-souris

Une souricière qui attire les rongeurs par l'odeur synthétique de fromage dégagée par le matériau dont elle est fabriquée est construit par l'Animal Trap Compagny de Litiz (Pennsylvanie).

## l'âne au théâtre

Shakespeare, dans le «Songe d'une Nuit d'Eté» met en scène un âne dont voici l'histoire. Jaloux de Tinania, Obéron, son époux lui a fait tomber sur les yeux quelques gouttes du suc d'une herbe magique. Celle-ci a le pouvoir de rendre amoureux du premier être vivant rencontré. Quant à Puck, il a doté le grossier Betton d'une tête d'âne. Bien entendu, c'est de ce personnage protesque entre tous que Titania s'énamoure toute de suite. Et c'est la scène 1 de l'acte IV au cours de laquelle on voit la reine faire une cour pressante à Betton et caresser ses longues oreilles.

## des teintures pour les moutons d'Australie

Les savants d'Australie ont trouvé un ingénieur moyen pour déterminer le taux de croissance de la laine sur des moutons placés dans des conditions déterminées. Les toisons sont marquées avec des colorants différents à intervalles réguliers. Il ne reste plus qu'à mesurer la hauteur qui sépare les repères colorés.

L'Australie, avec 159 millions de moutons, produit le tiers de la laine mondiale. Les exportations lainières représentent à peu près la moitié de la laine offerte sur le marché mondial.

# MEDECINE ET SANTE

## changement de cœur

Deux ans après une transplantation cardiaque, d'après les résultats publiés par des chirurgiens, les chiens qui avaient subi cette intervention avaient un cœur normal au repos et capables de s'adapter à l'exercice, donc normal là encore.

Le débit cardiaque et la pression dans le ventricule droit étaient normaux au repos et à l'exercice.

On observait une accélération du rythme des battements cardiaques à l'effort, ce qui est normal.

Les animaux, qui n'avaient jamais eu besoin de diurétiques ou de digitaliques depuis leur opération, ne présentaient aucun signe d'insuffisance cardiaque.

Ainsi, les performances du cœur transplanté sont, chez ces animaux, normales, ce qui suggère que du point de vue hémodynamique, il y aurait peu d'obstacles à l'homotransplantation cardiaque chez l'homme.

## un cœur artificiel

Le premier coeur artificiel de fabrication israélienne vient d'être construit par les ateliers de la Faculté de Physique appliquée du Technion, l'Institut technologique israélien à Haifa. L'appareil, commandé par l'Hôpital municipal Rambam de Haifa, a été essayé avec succès sur des animaux et il permettra prochainement d'effectuer des opérations du coeur. La construction de ce coeur artificiel par les ateliers de l'Institut technologique n'a duré que six mois, au lieu de délai de deux ans exigé pour les commandes passées à l'étranger.

La Faculté de Physique du Technion a un corps enseignant de 61 membres auxquels apportent leur aide 32 techniciens.

## c'est un jeune opéré !

Un enfant bleu âgé de 12 heures seulement vient d'être opéré avec succès par un chirurgien de Boston, et 24 autres ont ainsi été sauvés par des interventions chirurgicales effectuées peu de temps après leur naissance. Pour leur part, les chirurgiens de Houston (Texas) ont opéré aux cours des 9 dernières années, 500 enfants de moins d'un an, dont 363 ont ainsi échappé à une mort à peu près certaine.

## sana volant

On observe une nouvelle vague du dirigeable en U.R.S.S. Les futurs appareils destinés aux forestiers géologues ou tout simplement aux passagers transocéaniques, intéressent aussi les médecins soviétiques qui jugent que le dirigeable constitue un splendide sanatorium volant.

## des anévrismes soignés ... au poil !

Le Dr. John P. Gallagher, chirurgien de Washington, a imaginé un appareil, dessiné et construit par un technicien, Harriton P Hagemyer, qui contribue à la réduction des anévrismes cérébraux. Appelé Pilojector, cet appareil introduit des soies de porc ou du crin de cheval dans la partie malade du vaisseau sanguin sans déchirer celui-ci, tant l'opération est rapide. Le chirurgien place la canule de l'appareil à la surface de l'anévrisme dénudé. Un assistant envoie dans le corps de l'instrument de l'air comprimé qui fait pénétrer les poils dans l'anévrisme. Or ces poils, explique de Dr. Gallagher, contiennent d'innombrables écailles microscopiques qui attirent les cellules rouges et la fibrine du sang. Il se produit ainsi autour des soies ou du crin une coagulation qui contribue au renforcement de la section affaiblie et distendue du vaisseau sanguin

## la tuberculose ne tue plus

Pas de recrudescence de la mortalité tuberculeuse en France: le taux de mortalité, qui était évalué à 150 pour 100.000 habitants en 1930, est passé successivement à 111 en 1945, 58 en 1950, 23 en 1959, 21 en 1960, 19 en 1962.

## un matelas d'air

En Angleterre : «matelas d'air» pour le traitement des brûlés. Des jets d'air comprimé soulevant le malade évitent la compression des escarres et brûlures dorsales.

## statistiques

Le médecin américain moyen a fait 2.115 ordonnances au cours de l'année dernière. Le total des ordonnances, établies en Amérique, a représenté 2,26 milliards de dollars. On prévoit qu'en 1965, elle atteindront 3 milliards de dollards et 5 milliards de dollars en 1970 d'après l'augmentation démographique.

## tous les habitants sont examinés

Dans une petite ville américaine de 10.000 habitants, Sudbury, on prévoit d'examiner systématiquement toutes les personnes âgées de plus de 15 ans.

Cette étude est destinée à l'établir la fréquence des maladies chroniques. Elle est entreprise par le Service de la Santé Publique et est menée avec la collaboration de 11 médecins de cette ville.

Elle a commencé depuis quelques mois. Les habitants semblent très coopérants; en quelques semaines 4.000 des 6.000 questionnaires envoyés ont été remplis et renvoyés.

L'examen qu'on prévoit de faire subir à tous les habitants comporte une grande variété de recherches et de test: antécédents médicaux, électrocardio-gramme, examen d'urines (recherche du glucose, du Phi, de l'acétone du sang, des protéines( examen sanguin (cholestérol), mesure du panicule adipeux, recherche de signes d'arthrite rumatoide et de maladies du collagène, etc...

La population de cette ville semble représentative de l'américain moyen, et on espère établir à partir de cette étude des normes nationales pour les maladies étudiés.

## des robots pour essayer les abris atomiques

De petits robots seront placés dans les abris atomiques afin d'étudier les conditions de survie de l'homme dans un espace restreint.

Conçus par des ingénieurs de l'Université de Floride, les Simocs (simulated occupants ) reproduisent les phénomènes physiques , chimiques et thermiques de la vie. Le simoc se nourrit, dort et transpire.

Mesurant environ 1 mètre 20, son corps cylindrique est entouré (sur la moitié inférieure) d'un revêtement spongieux, sorte de lange qui lui permet d'absorber l'humidité. Un générateur calorifique maintient sa température à 37° C. Les ingénieurs en attendent beaucoup d'informations, notamment sur la façon dont un être humain réagirait pendant une longue période à l'intérieur d'un abri.

## pénurie !

Le ministère de la Santé Publique précise qu'il y a en France dans le secteur public une infirmière pour 7,5 lits d'hospitalisation. Or, les normes admises couramment sont de une pour trois lits!

# មហាសន្និបាតសាមញ្ញ

## ឆ្នាំ 1964



គណកម្មាធិការនាយកថ្មី ។ រូបថត គោសា

មហាសន្និបាតសាមញ្ញឆ្នាំ ១៩៦៤ នៃស.ស.ខ. បានបើកសម័យប្រជុំនៅទីស្នាក់ការរបស់ខ្លួន (ជាលើកដំបូងបង្អស់) នៅថ្ងៃអាទិត្យ ៩ សីហា ១៩៦៤ វេលាម៉ោង៨កន្លះក្រោមអធិបតីភាពនៃមិត្ត កែ សុខន ប្រធាន ។

បានអញ្ជើញមករួមមហាសន្និបាត ក្រៅអំពីសមាជិកគណៈកម្មាធិការ មានអស់មិត្តតំណាង ស.ស.ខ. តាមអាគារទីងក្រសួងផ្សេងៗ អស់មិត្តសមាជិកមួយចំនួន ហើយនិងអស់មិត្តមួយចំនួនទៀត ដែលបានមកធ្វើមេប្រយោគប្រឡងសញ្ញាបត្រលើកទី ២ ។

# កិច្ចការសមាគម

បន្ទាប់ពីបានធ្វើសេចក្ដីរាយការមួយប្រកបទៅដោយសុទិដ្ឋិនិយមមក មិត្តប្រធានបានជូនសម្មេនទៅអគ្គលេខាធិការ និងអគ្គហិរញ្ញិក ដែលរាយការរបស់ខ្លួនជាបន្តបន្ទាប់គ្នា (សូមអានអត្ថបទទៅខាងក្រោយ) ។

លុះការបោះឆ្នោតជ្រើសរើសសមាជិកនៃ គ.ន. ថ្មី បានប្រព្រឹត្តទៅរួចហើយ (សូមមើលលទ្ធផលទៅខាងក្រោយ) ការពិភាក្សាអំពីសេចក្ដីរាយការក៏បានធ្វើឡើង ។

នៅក្នុងអន្តរាគមន៍របស់ខ្លួន មិត្តជាច្រើននាក់បានធ្វើការចាប់អារម្មណ៍ជាបន្តបន្ទាប់គ្នា អំពីសកម្មភាពនៃ គ.ន. ដែលទោះបីជាក្នុងកាលៈទេសៈវិបត្តិខ្លះផងក៏ដោយ ក៏នៅតែបានខំពុះពារញុំាងសមាគមឲ្យធ្វើដំណើរទៅមុខបានជាធម្មតាដដែល ពុំនោះសោតទេ គឺបានប្រសើរជាងឆ្នាំមុនៗទៀតផង ។ មហាសន្និបាតបានបញ្ចេញយោបល់យ៉ាងវែងអំពីភារៈតំណាង ហើយបានអំពាវនាវដល់មិត្តតំណាងទាំងឡាយឲ្យមេត្តាយកចិត្តទុកដាក់បំពេញភារៈរបស់ខ្លួនឲ្យបានជិតដល់ ព្រមទាំងអំពាវនាវដល់សមាជិកឲ្យរំលឹកនឹងជួយការងារមិត្តតំណាងផង ។

សំណូមមួយទៀត ស្ដីអំពីការទាក់ទងគ្នាៗ មហាសន្និបាតបានសូមឲ្យគ.ន ថ្មី បង្កើនការទាក់ទងជាមួយនឹងមិត្តតំណាង ហើយនឹងសមាជិកឲ្យបានជិតដល់ថែមទៀត ហើយឲ្យមានផែនការសកម្មភាព មួយប្រចាំឆ្នាំៗ "ការទាក់ទងបានជិតដល់ ភាគខាងក៏បានទៀងទាត់ដែរ" ។ ឯការយោគយល់គ្នាក៏នឹងស្គាល់កំរិតមួយថ្មីទៀត ។

ចំពោះអត្ថបទទស្សនាវដ្ដី មហាសន្និបាតបានអំពាវនាវឲ្យមិត្តទាំងឡាយ

ជួយផ្ដល់ផង ។ មិត្តអាចនឹងផ្ដល់អត្ថបទបែបណាក៏បានគឺ: អត្ថបទជាជំរៅ ( article de fond) អំពីការសិក្សាក្នុងប្រទេសនិងនៅបរទេស—បញ្ហាវប្បធម៌ —វិទ្យាសាស្ត្រនិងសិល្បៈ —ជីវភាពមិត្តយើង —ស្ទូរជួងសាលា – អត្ថបទនិងឯកសារ (វប្បធម៌ទូទៅ ) —រឿងកំសាន្តខ្លីៗ—គំនូរកំប្លែងស្លូត(humour)—ពាក្យខ្វែង...។ ប្រសិនបើមិត្តមានការលំបាកក្នុងការនិពន្ធ មិត្តអាចនឹងផ្ញើតែគោលៗមកក៏បានដែរ ។ គ ន នឹងរចនាយ៉ាងណាឲ្យបានសមនឹងបំណងរបស់មិត្ត ។ មិត្តអាចសរសេរជាបារាំងក៏បាន (ប្រសិនបើមិត្តចង់ យើងនឹងប្រែជូន) ។

នៅក្នុងរបៀបវារៈចុងក្រោយបង្អស់ មហាសន្និបាតបានអនុម័តជាឯកច្ឆន្ទនូវ **សេចក្ដីសំរេចចិត្ត** មួយច្បាប់ថ្វាយអ្នកអង្គម្ចាស់នាយករដ្ឋមន្ត្រី និងជូនឯកឧត្តមប្រធានរដ្ឋសភា ដើម្បីប្រឆាំងនឹងចក្រពត្តិអាមេរិកាំងហើយនិងរដ្ឋការព្រៃនគរដែលបានបង្កើត **សង្គ្រាមគីមី** សម្រាប់ពលរដ្ឋខ្មែរជើងស្លូតត្រង់របស់យើងនៅរតនគិរី និងនៅស្វាយរៀង ហើយប្រឆាំងនឹងចក្រពត្តិអាមេរិកាំងនិងពួកព្រៃនគរ ដែលចាប់ផ្ដើមអនុវត្តផែនការម៉ាក់-ណាម៉ារ ពង្រីកសង្គ្រាមទៅវៀតណាមខាងជើង ( សូមអានសេចក្ដីសំរេចចិត្តទៅខាងក្រោយ)។

មហាសន្និបាតបានប្រព្រឹត្តទៅអស់រយៈពេលបីម៉ោងកន្លះ ហើយបានបញ្ចប់សព្វគ្រប់នៅម៉ោង ១២ ក្នុងបរិយាកាសរីករាយនិងក្នុងសាមគ្គីភាពជិតស្និទ្ធយ៉ាងក្រៃលែង ។

◙

**សូមអភ័យទោស!**

ការយឺតយ៉ាវនឹងអាក់ខានចេញព្រឹត្តិបត្រប្រចាំខែ បណ្ដាលមកអំពីការយឺតយ៉ាវរបស់រោងពុម្ព ដែលនាំឱ្យយើងមានការរារែកជាខ្លាំង ។

# សេចក្ដីរាយការណ៍សកម្មភាព
# របស់មិត្តអគ្គលេខាធិការ

គួប គៅសា

មិត្តទាំងឡាយ

ចាប់តាំងពីបានទទួលសេចក្ដីទុកចិត្តពីមហាសន្និបាតពេលណាមក សមាជិកទាំងអស់នៃគណៈកម្មាធិការនាយក បានខិតខំអស់សមត្ថភាព ដើម្បីនឹងពួតដៃគ្នាបំរើសមាគម ៗ ក្នុងឆ្នាំនេះមិត្តប្រធាន ( កែ សុខន ) ក៏ត្រូវផ្លាស់ទៅវិទ្យាល័យព្រះអង្គឌួង ហើយប៉ុន្មានខែបន្ទាប់មក មិត្តអគ្គលេខាធិការ (ខែក ប៊ុន) ក៏ត្រូវផ្លាស់ទៅទៀត ៗ ប៉ុន្តែមិត្តដែលនៅសល់ទាំងប៉ុន្មាន បានរួមគ្នាជាធ្លុងមួយធ្វើដំណើរទៅមុខយ៉ាងស្វាហាប់ ៗ ចំណែកឯមិត្តសមាជិកនៅភ្នំពេញក៏ដូចជានៅខេត្តក្រៅ ក៏បានខំផ្ដល់នូវវិភាគទានតាមសមត្ថភាពរៀងៗខ្លួន ជាហេតុធ្វើឲ្យសាមគ្គីភាពរវាងគ.ន.និងសមាជិកមានរូបរាងកាន់តែធាត់ធំជាងមុនច្រើនៗ ទាំងនេះហើយជាមូលហេតុនៃសេចក្ដីរីកចំរើនរបស់សមាគមយើងៗ

## I· ខាងសម្ភារៈ

តាំងតែពីសមាគមយើងបានទីស្នាក់ការនេះនិងបានលេខាធិការមកដំណើរការបានប្រព្រឹត្តទៅស្រួលហើយឆាប់រហ័សជាងមុនច្រើន ៗ ទីស្នាក់ការយើងងាយរកឃើញ ងាយចេញចូល ស្រួលធ្វើការល្មម; លេខាធិការយើងមានសមត្ថភាពមធ្យម ៗ តុ កៅអីនិងទូប៉ុណ្ណោះ យើងបានទិញសំរាប់ការចាំបាច់ជាដំបូងសិន ៗ បណ្ណាល័យតូចមួយរបស់យើងមានសៀវភៅល្អៗមួយចំនួនដែលជាអំណោយនិងការយកមកទុកឲ្យខ្ចីនៃមិត្តយើងខ្លះ ហើយនិងវចនានុក្រម ២ក្បាលដែលយើងបានទិញ ៗ ម្យ៉ាងទៀតយើងក៏បានទិញ មុងនិងកន្ទេលខ្លះ សំរាប់មិត្តយើងណាដែលត្រូវការមកសំណាក់

មួយជន់មួយកាល (ដោយបានឲ្យដំណឹងជាមុន) ។

តាមសេចក្ដីសុំពីមហាសន្និបាតឆ្នាំមុន យើងបាន បោះបណ្ណសមាជិកថ្មី ហើយមានសមាជិកជាច្រើនក៏បានផ្ញើរូបថតមកយកបណ្ណថ្មីនេះហើយ ។ យើងស្ដាយត្រង់មិនទាន់អាចធ្វើ «album» បាន ដោយមិនទាន់បានទទួលរូបថតពីគ្រប់មិត្តយើងនៅឡើយ ។ ចំណែកឯលក្ខន្តិកៈ យើងពុំទាន់បានបោះជាថ្មីទេ ដោយសំគាល់ថាយើងទើបតែនឹងកែប្រែដែរ ។

ឆ្នាំនេះ គ.ន.យើងបានចេញ ព័ត៌មាន ប្រចាំខែបាន៣ លើកគឺ ខែកក្កដា ១ ខែកញ្ញា-តុលា-វិច្ឆិកា១ នឹងខែកុម្ភៈ១ ហើយចេញទស្សនាវដ្ដីបាន៤លេខត្រឹមត្រូវតាមគ្រោងការដែលបានកំណត់ ។ ចំពោះការយឺតយ៉ាវខ្លះ ការនេះបណ្ដាលមកពីការខ្វះខាតអត្ថបទ ប៉ុន្តែជាពិសេសគឺមកពីរោងពុម្ព ។

## II. ខាងសុខទុក្ខមិត្ត

ទោះបី គ.ន. មានគ្នាតិចដូចនេះក្ដី ក៏មិត្តយើងបានខិតខំខ្វាយខ្វល់ដល់បញ្ហាសុខទុក្ខនៃមិត្តយើងដោយអស់សមត្ថភាពដែរ ស្របតាមគំនិតនឹងគោលបំណងនៃសមាគមយើង ។

យើងបានធ្វើតាមលទ្ធភាពរបស់ខ្លួន ដើម្បីទៅចូលរួមសុខទុក្ខនៃមិត្តយើង ដូចជា ក្នុងអាពាហ៍ពិពាហ៍ក្នុងការសំរាលកូន ក្នុងការព្យាបាលរោគនៅមន្ទីរពេទ្យ ក្នុងការប្រឡងជាប់ ក្នុងពេលមានគ្រោះថ្នាក់ ..... ។

នៅពេលក្រោយបង្អស់នេះ យើងបានទុយន៍សៀតសាស្ត្រាចារ្យមួយចំនួនដែលចង់សិក្សាក្នុងវិស្សមកាល ខ្ចីទីស្នាក់ការយើងធ្វើជាសាលសហសិក្សា ។ ( ក្នុងសេចក្ដីរាយការណ៍របស់ខ្លួន មិត្តតៅសាបានរៀបរាប់ឈ្មោះនៃមិត្តយើងទាំងអស់ដែលគ.ន.បានទាក់ទងសួរសុខទុក្ខ ) ។

ឃើញថា បងប្អូនគ្រួសារសាស្ត្រាចារ្យយើងបានស្គាល់សុខទុក្ខគ្នា បានទាក់ទង



មហាសន្និបាត (៩សីហា ១៩៦៤) កំពុងតែប្រុងស្ដាប់សេចក្ដីអន្តរាគមន៍របស់មិត្តយើងជាច្រើន ។ ពៅសា

គ្នាពីសាលាមួយទៅសាលាមួយ បានស្គាល់ជីវភាពគ្នាគ្រាន់បើជាងឆ្នាំមុនច្រើន ។ ប៉ុន្តែការខ្វះខាតក៏នៅមានច្រើននៅឡើយដែរ ជាហេតុនាំឲ្យមិត្តខ្លះមើលពីក្រោមគមិនយល់ក៏មានការអាក់អន់ចិត្តបន្តិចបន្តួចដោយអចេតនា ដោយឃើញថាគ្រួសារយើងហាក់ដូចជាខ្វះសមភាពជាដើម ។

ដូចជាបានសង្កេតថា កាលបើមិត្តខ្លះរៀបអាពាហ៍ពិពាហ៍មានសុខទុក្ខអ្វី នោះមានដំណឹងក្នុងទស្សនាវដ្ដី លុះមិត្តខ្លះមានទុក្ខធុរៈវិញគ្មានដំណឹងក្នុងទស្សនាវដ្ដីសោះៗ ក្នុងខនេះ គ.ទ.មានគុណវិបត្តិម្យ៉ាងត្រង់មិនបានផ្ញើសំបុត្រទៅសាកសួរមិត្តតំណាងគ្រប់ៗគ្នាឲ្យបានទៀងទាត់ ប៉ុន្តែការផ្ដល់ដំណឹងរបស់សមាជិកដល់ គ.ទ.នេះជាការៈធំរបស់មិត្តតំណាងហ្នឹងឯងហើយ ដូចតែការប្រមូលភាគទាន និងការចែកទស្សនាវដ្ដីប្ដូរពត៌មានផ្សេងៗពី គ.ទ. ដូចនេះដែរ ។ ប្រសិនបើមិត្តតំណាងរាយមាយក្នុងការផ្ដល់ដំណឹងនេះ គ.ទ.ពិបាកឬមិនអាចទទួលដំណឹងផ្សេងៗពីមិត្តយើងបានឡើយ លើកលែងតែប៉ះដោយ

ថៃជន្យតៃមួង ។ មិត្តតំណាង«ជាភ្នែកជាច្រមុះ»នៃ គ.ន. នៅក្នុងសាលានិមួយៗ ។ ប៉ុន្តែការខ្វះខាតនៃមិត្តតំណាងមិនបិតតែក្នុងខេនេះទេ ទោះជាក្នុងខេភាគពាន ក៏ដូចនេះដែរ។

## III· ការទាក់ទងខាងក្រៅ

ក្នុងផ្នែកនេះ មិត្ត ទីវ អ៊ិល ទឹង គូច តៅសា បានទៅក្រាបថ្វាយបង្គំសម្តេចព្រះសំឃរាជថ្នាក់ទី១ដើម្បីទឹងស្តាប់ព្រះដំបូន្មានអំពី«ផ្លូវដែលបញ្ញាវន្តត្រូវដើរដើម្បីឲ្យបានទៅជាបណ្ឌិតមានប្រយោជន៍ដល់ប្រទេសជាតិ,, ហើយបានសរសេរអត្ថបទមួយតាមពន្ធ័នៃព្រះគតិព្រះអង្គ ។

ម៉្យាងទៀត

១. ក្នុងឱកាសចូលឆ្នាំថ្មីកន្លងទៅនេះ គ.ន. ៖

  – បានថ្វាយព្រះពរសម្តេចព្រះសំឃរាជទាំង ២ គណៈ

  – បានថ្វាយព្រះពរសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ (មិត្តតៅសា អានព្រះសារលិខិតឆ្លើយតប )

  – បានថ្វាយព្រះពរសម្តេចឪ ( មិត្តតៅសា អានព្រះសារលិខិតតប )

២. ក្នុងឱកាសពិធីបំរើនព្រះជន្ម បានថ្វាយព្រះពរសម្តេចឪ

៣. បានថ្វាយព្រះពរសម្តេចឪ ក្នុងឱកាសព្រះអង្គយាងទៅព្យាបាលព្រះរោគឯប្រទេសបារាំង

៤. បានប្រគេនរូបសំណាកសម្តេចឪ ដល់សម្តេចព្រះពោធិវង្ស ក្នុងពេលសម្ពោធអាគារព្រះសីហនុ

៥. បានផ្ញើសេចក្តីសាទរថ្វាយអ្នកអង្គម្ចាស់ស៊ីសុវត្ថិ សិរីមត្តៈ នៅពេលព្រះ-អង្គឡើងកាន់តំណែងជាទេសរដ្ឋមន្ត្រីទទួលបន្ទុកខាងអប់រំជាតិ និងវិចិត្រសិល្បៈ ( ព្រះលិខិតឆ្លើយតប )

## IV . បញ្ហាប្រទេសជាតិ

ដូចមិត្តយើងជ្រាបស្រាប់ហើយថា ក្នុងឆ្នាំកន្លងទៅនេះ ប្រទេសយើងត្រូវចក្រពត្តិលោក «សេរី» ដែលមានចក្រពត្តិអាមេរិកាំងជាមេធំបរិវារ មានពួកអាយ៉ងព្រៃនគរ–បាងកកនិង "ខ្មែរសេរី" ជាកញ្ឆះបន្តមកទៀត បានបុករុកស្រុកយើងឥតស្រាកស្រាន្តៗ ពីខាងក្នុងប្រទេសយើងមាន ពួកអាសុងសាក់ បានប៉ង់ធ្វើរដ្ឋប្រហាររំលំសម្តេចឪ ដែលជាអាយុជីវិតនៃប្រជាជាតិខ្មែរទាំងមូល ដូចព្រះរាជបន្ទូលនៅបាត់ដំបង កាលពី២-៣ថ្ងៃមុននេះស្រាប់ ៗ

ដើម្បីតទល់នឹងចោរហិង្សាខាងលើនេះ មហាជនខ្មែរទាំងមូល មានព្រះសំឃ យុវជន កម្មករជាដើម បានរែកម្មាទនឹងវាយកំទេចផែនការក្បត់របស់ពួកវាយ៉ាងសកម្មៗ

ឯសមាគមយើងក៏មិនបាននៅឈរ ឱបដៃមើលដែរ ៗ ហេតុនេះហើយ បានជាសមាគមយើង បានចូលខ្លួនទៅក្នុងជួរព្រះសំឃ យុវជននិងកម្មករ ទាំងនោះ ដើម្បីរួមចំណែកការពារប្រទេសយើងដែរ ៗ ដូចជា៖

១- បានធ្វើញត្តិប្រឆាំងចក្រពត្តិអាមេរិកនិងបរិវារ ដែលបង់រំលំអព្យាក្រឹតភាពខ្មែរ ( ៣ សីហា ១៩៦៣)

២. ថ្វាយញត្តិសម្តេចឪ ដើម្បីគាំទ្រព្រះរាជនយោបាយជាតូបនិយកម្ម អាហរណ៍ – និហរណ៍ ធនាគារ សុភការ

### លទ្ធផលនៃការបោះឆ្នោត

| | | | |
|---|---|---|---|
| មិត្ត | អឹម សារឿន | ៤៨ | សម្លេង |
| — | ទីវ អុល | ៤៣ | — |
| — | ឡឹក រ៉េន | ៤៣ | — |
| — | គួច តៅសា | ៤៣ | — |
| — | កែ សុវន | ៤៦ | — |
| — | ណាង ហាប់អាន | ៤៣ | — |
| — | ធុច រិន | ៤២ | — |
| — | កែ គឹមហួត | ៣៨ | — |
| — | មាស ឌឹម | ៣៥ | — |
| — | កង សារ៉ែន | ២៦ | — |

ប្រឹក្សា

លោក សូ ណៃម

— អ៊ុល ធនូ

ការធានាក៏ប៉ះង និងការទាត់ចោលនូវជំនួយអាមេរិកាំង ទាំងយោធា ទាំងសេដ្ឋកិច្ចនិងវប្បធម៌(៦តុលា១៩៦៣)

៣. ញត្តិប្រឆាំងបក្រពត្តិអាមេរិក-ព្រៃនគរ-ខ្មែរសេរី ហើយប្ដេជ្ញាដង្ហែតាមសម្ដេចឪ តែមួយព្រះអង្គ ( ២០ មីនា ១៩៦៤ )

៤. អំពាវនាវឲ្យមិត្តឆ្លើយនឹងការមួលបង្កាច់របស់ ថាណាត ខូម៉ាន់

៥. ឆ្លើយតបនឹងការផ្សាយវិទ្យុនារបស់ "ខ្មែរសេរី" ដែលមានជនក្បត់ សារី-ថាន់ ជាមេ

៦. ជួយរំលែកទុក្ខបងប្អូនរងគ្រោះនៅភូមិចន្ទ្រា ដែលបណ្ដាលមកអំពីការឈ្លានពាននៃអាមេរិក-ខាញ់ ដោយចូលបច្ច័យ ១.០០០ រៀល ។

ឯសកម្មភាពចុងក្រោយបង្អស់ គឺការរៀបចំពិធីជុបលៀងប្រចាំឆ្នាំកាលពីល្ងាចមិញនេះឯង ។


ទើបតែនឹងបើកថ្មី

**បណ្ណាគារ អន្តរជាតិ** មហាវិថី នេរូ ភ្នំពេញ **150 G**

សូមអញ្ជើញ មិត្តសមាជិក នៃសមាគមសាស្ត្រាខ្មែរ

ទៅទិញសៀវភៅនៅបណ្ណាគារនេះ !

រង្វាន់ ២០ភាគរយ នឹងមានធ្វើជូនចំពោះមិត្តណាដែល
ទៅទិញ ហើយបានបង្ហាញបណ្ណសមាជិក,

មានលក់សៀវភៅសិក្សា សៀវភៅប្រលោមលោកជាភាសាខ្មែរនិងជាភាសាបារាំងមានលក់ទស្សនាវដ្ដីដែលផ្សាយចេញនៅប្រទេសចិន វៀតណាមនិងនៅសហភាពសូវៀត ហើយនិងសៀវភៅសំរាប់បណ្ដុះវប្បធម៌ទូទៅជាច្រើនមុខទៀតជាភាសាបារាំង និង "អេស្ប៉េរ៉ង់តូ" ព្រមទាំង... រូបតុក្កតាផង

# សេចក្ដីរាយការណ៍ ហិរញ្ញវត្ថុ របស់មិត្តអគ្គហេរញ្ញិក (ឡើកវ៉ែន)

## ចំណាយក្នុងឆ្នាំ ១៩៦៣-៦៤

| លេខរៀង | មុខចំណាយ | តម្លៃ | | កាលបរិច្ឆេទ |
|---|---|---|---|---|
| 1 | ឈ្នួលស្នាក់ការទី១ សំរាប់ខែសីហា ១៩៦៣ | 1.200 | រៀល | 30-7-6 |
| 2 | — ទី ២ — ១៩៦៣ | 1.500 | – | — |
| 3 | បៀវត្សស្មៀន សំរាប់ខែកក្កដា ១៩៦៣ | 1.000 | — | — |
| 4 | ក្រដាស់ duplicata | 296 | — | 16-8-63 |
| 5 | គ្រីសេសំរាប់សញ្ញាណប័ត្រ | 60 | — | 17-8-63 |
| 6 | សោហ៊ុយ | 53 | — | 19-8-63 |
| 7 | ក្រដាស់រូណេអូ ៥ រ៉ាម | 189 | — | — |
| 8 | បោះពុម្ពក្បាល ព្រឹត្តិបត្រ | 500 | — | 20-8-93 |
| 9 | ឈ្នួលទីស្នាក់ការ សម្រាប់ខែកញ្ញា | 1.500 | — | 30-8-63 |
| 10 | បៀវត្សស្មៀន | 1.000 | — | — |
| 11 | ចំណាយផ្សេង ៗ សំរាប់ខែកក្កដា នឹង សីហា | 598 | — | — |
| 12 | ឈ្នួលទីស្នាក់ការសំរាប់តុលា ១៩៦៣ | 1.500 | — | 30-4-63 |
| 13 | បៀវត្សស្មៀនស់រាប់កញ្ញា ១៩៦៣ | 1.000 | — | — |
| 14 | បោះពុម្ពសញ្ញាណប័ត្រ ២០០០ សន្លឹក | 1.400 | — | 16-10-63 |
| 15 | ត្រាសង្កត់ | 1.500 | — | 31-10-63 |
| 16 | ចំណាយផ្សេង ៗ សំរាប់តុលា | 260 | — | — |
| 17 | បៀវត្សស្មៀន ក្នុងខែ តុលា ១៩៦៣ | 1.000 | — | — |
| 18 | ឈ្នួលទីស្នាក់ការ សំរាប់ខែវិច្ឆិកា ១៩៦៣ | 1.500 | — | — |
| 19 | ក្រដាស់រូណេអូ ១០ ដុំ | 414 | — | 30-11-63 |
| 20 | ចំណាយផ្សេង ៗ សំរាប់ខែវិច្ឆិកា | 495 | — | — |
| 21 | បៀវត្សស្មៀនសំរាប់ខែវិច្ឆិកា ១៩៦៣ | 1.000 | — | — |
| 22 | ឈ្នួលទីស្នាក់ការក្នុងខែធ្នូ ១៩៦៣ | 1.500 | — | — |
| 23 | គ្លីសេរូ រូបសម្ដេចឳ | 183 | — | 20-12-63 |
| 24 | បៀវត្សស្មៀន ក្នុងខែធ្នូ ១៩៦៣ | 1.000 | — | 30-12-63 |
| 25 | ឈ្នួលទីស្នាក់ការសំរាប់ខែមករា ១៩៦៤ | 1.500 | — | — |
| 26 | ទស្សនាវដ្ដី ១១-១២ | 15.572 | — | — |

| | | | | |
|---|---|---|---|---|
| 27 | គ្លីសេ ៣ សំរាប់បំណាងផើង | 125 | រៀល | 21-1-64 |
| 28 | សន្ទឹកបន្ថែមលើទស្សនាវដ្ដី ១១-១២ | 1.025 | — | — |
| 29 | បំណាយផ្សេង ៗ សំរាប់ខែធ្នូ នឹងមករា | 583 | — | — |
| 30 | បៀវត្សស្មៀន ក្នុងខែ មករា ១៩៦៤ | 1.000 | — | 31-1-64 |
| 31 | ឈ្នួលទីស្នាក់ការ ក្នុងខែ កុម្ភៈ ១៩៦៤ | 1.500 | — | — |
| 32 | វចនានុក្រម ខ្មែរ ២ ក្បាល | 540 | — | 20-2-64 |
| 33 | ទូកញ្ចក់ពីរ | 2700 | — | — |
| 34 | ក្រដាស់រូណេអូ ៥ ដុំ | 222 | — | 26-2-64 |
| 35 | ទិញក្របជូនមិត្តសមាជិកម្នាក់ឈឺ | 90 | — | 5-3-64 |
| 36 | ជំនួយដល់អ្នករងគ្រោះនៅបន្ទ្រា | 1.000 | — | 26-3-64 |
| 37 | បៀវត្សស្មៀន ក្នុងខែ មីនា ១៩៦៤ | 750 | — | — |
| 38 | បៀវត្សស្មៀន ក្នុងខែមេសា ១៩៦៤ | 1.000 | — | 30-4-64 |
| 39 | ឈ្នួលទីស្នាក់ការ — | 1.300 | — | — |
| 40 | គ្លីសេ "យើងឆ្លើយឆ្លងគ្នា,, | 73 | — | — |
| 41 | គ្លីសេ " Système scolaire ,, | 277 | — | — |
| 42 | សៀវភៅបញ្ជី ២ ក្បាល | 90 | — | — |
| 43 | បំណាយផ្សេង ៗ សំរាប់ខែកុម្ភៈ ១៩៦៤ | 1.381 | — | — |
| 44 | — ខែមីនា នឹង មេសា | 247 | — | — |
| 45 | ឈ្នួលទីស្នាក់ការសំរាប់ខែឧសភា ១៩៦៤ | 1.300 | — | 1-6-64 |
| 46 | បៀវត្សស្មៀន — | 1.000 | — | — |
| 47 | ទស្សនាវដ្ដីទី ១៣ | 10.320 | — | — |
| 48 | ក្របទស្សនាវដ្ដីទី ១៣ | 1.080 | — | — |
| 49 | ក្រដាស់ខ្ចប់ | 60 | — | — |
| 50 | បំណាយផ្សេង ៗ សំរាប់ខែឧសភា នឹង មិថុនា | 1.157 | — | 1-7-64 |
| 51 | ឈ្នួលទីស្នាក់ការ | 1.300 | — | — |
| 52 | បៀវត្សស្មៀន | 1.000 | — | — |
| 53 | រូបសំណាកសម្ដេចឪ | 180 | — | — |
| 54 | គ្លីសេសំរាប់ក្របទស្សនាវដ្ដីទី ១៤ | 540 | — | 18-7-54 |

| | | | | |
|---|---|---|---|---|
| 57 | បៀរត្បស្មៀន | 1.000 | រៀល | 1-8-64 |
| 58 | ឈ្នួលទីស្នាក់ការ | 1.300 | — | - |
| 59 | ទស្សនាវដ្តី ទី ១៤ | 20.164 | — | 6-8-64 |
| | បូករួម | 93.183 | — | |

*ឯប្រាក់ចំណូលទាំងអស់បានផ្សាយរួចស្រេចហើយក្នុងទស្សនាវដ្តីមុនសរុបទាំងអស់គឺ ៩០.៨៣៣រ ។*

*ប្រាក់ចំណាយត្រូវលើសដល់ទៅ ២.៣៨០រ ។ ហេតុការនេះបណ្តាលមកពីមិត្តតំណាងខ្លះពុំទាន់បានផ្ញើវិភាគទានរបស់ខ្លួនមកមន្ទីរបាត់ការ ។*

*តទៅមកគណៈកម្មាធិការនាយកបានទទួលពី ៖*

| | | |
|---|---|---|
| អនុវិទ្យាល័យ ស្ទឹងត្រង់ | 700 | រៀល |
| — គន្ធបុប្ផា | 1000 | — |
| — ព្រះសោមា | 1000 | — |
| វិទ្យាល័យ ព្រះអង្គឌួង | 5830 | — |
| អនុវិទ្យាល័យ តាំងគោក | 1560 | — |
| និស្សិតសាស្ត្រាចារ្យ | 400 | — |
| វិទ្យាល័យ ព្រះស៊ីសុវត្ថិ | 1660 | — |
| អនុវិទ្យាល័យបច្ចេកទេស កំពង់ចាម | 3920 | — |
| — ព្រៃកពោធិ | 880 | — |
| វិទ្យាល័យ ព្រះសីហនុ | 2000 | — |
| អនុវិទ្យាល័យ កំពង់ត្របែក | 2560 | — |
| វិទ្យាល័យ កំពង់ធំ | 1600 | — |
| អនុវិទ្យាល័យ សន្តិភាព | 1140 | — |
| — ព្រៃដើមថ្នឹង | 1020 | — |
| — ទេពប្រណម្យ | 920 | — |
| — សន្តិភាព | 320 | — |
| — សុរិយោវង្ស | 1117 | — |
| បូករួម | 27.627 | — |

**កិច្ចការសមាគម ៥**

■ ក្នុងឱកាសមហាសន្និបាតឆ្នាំ ១៩៦៤ ដែលទើបនឹងកន្លងទៅនេះ សមាជិកមហាសន្និបាតបានសំរេចដាក់ជូនឲ្យគណៈកម្មាធិការនាយកធ្វើសេចក្ដីសំរេចចិត្តមួយបង្ហាញអាកប្បកិរិយាសមាគមចំពោះអំពើព្រៃផ្សៃឃោរឃៅរបស់ចក្រពត្តិអាមេរិកនឹងបរិវារព្រៃនគរ ដែលបានព្យាយាមប្រើគ្រប់ឧបាយកលដើម្បីនឹងរំលំឯករាជ្យ បូរណភាពដែនដី និងអព្យាក្រឹតភាពដ៏ថ្លៃថ្លារបស់ខ្មែរយើង ។

សេចក្ដីសំរេចចិត្តនេះសរសេរជា ២ ច្បាប់ មួយច្បាប់ថ្វាយអ្នកអង្គម្ចាស់នាយករដ្ឋមន្ត្រី មួយច្បាប់ទៀតជូនឯកឧត្តមប្រធានរដ្ឋសភា ។

ខាងក្រោមនេះជាអត្ថបទទាំងស្រុងនៃសេចក្ដីសំរេចចិត្ត ។

គណៈកម្មាធិការនាយក
នៃសមាគមសាស្ត្រាចារ្យខ្មែរ
១២៣ E វិថីព្រះសីហនុ
ភ្នំពេញ

## សេចក្ដីសំរេចចិត្ត
## នៃមហាសន្និបាត សមាគម សាស្ត្រាចារ្យខ្មែរ

*បន្ទាប់ពីបានដឹងតាមវិទ្យុមកថា កាលពីថ្ងៃ ១៣ និង២០មិថុនា ថ្ងៃ ៩-១៧-២០-២១-២២ និង ២៣ កក្កដានេះ យន្តហោះអាមេរិក-វៀតណាមខាងត្បូងបានចូលរំលោភដែនអាកាសខ្មែរ ហើយបានបាញ់កាំភ្លើងទំលាក់លើភូមិកេះចុង ភូមិប៉ក់ញៅ ប៉ក់ពោលា មាក់ជាង កាម៉ង់ចុង និងភូមិបូឡយ ក្នុងស្រុកអណ្ដូងពេជ្រ ខេត្ររតនគិរី បណ្ដាលឲ្យពលរដ្ឋខ្មែរស្លូតត្រង់ទទួលមរណភាពរហូតមកទល់នឹងពេលនេះអស់ ៨៦ នាក់ ដោយធំរីមួលពោះវៀន ហើយបណ្ដាលឲ្យសត្វពាហនៈនិងដំណាំដាំដុះស្លាប់វិនាសអស់ជាច្រើនទៀត ,*

*បន្ទាប់ពីបានដឹងតមកទៀតថា កាលពីថ្ងៃ ៣០ កក្កដា និងយប់ថ្ងៃ ៤ សីហា ១៩៦៤ នេះ យន្តហោះរបស់រដ្ឋការចក្រិដ្ឋជដែល បានចូលរំលោភដែនអាកាសខ្មែរ ត្រង់ខេត្រស្វាយរៀង ហើយបានបាញ់កាំភ្លើងមីបន្តមកទៀត បណ្ដាលឲ្យពលរដ្ឋខ្មែរ៥០ប្រាំបួននាក់និងសត្វពាហណៈភូមិប្រកម្ទេះ ភូមិព្រៃគគី និងភូមិពពែត រងទុក្ខវេទនាជាទម្ងន់ ,*

ដោយយល់ថាអំពើឧក្រិដ្ឋទាំងប៉ុន្មាននេះរបស់ចក្រពត្តិអាមេរិក និងបរិវារព្រៃនគរជាអំពើអនារ្យធម៌ហ្វាស៊ីសផុតលេខ រកឈ្មោះដាក់គ្មានដែលសីលធម៌និងមនុស្សជាតិទាំងមូលបានក្រែងរអែង បានខ្ទើមខ្ពើមនិងផ្តន្ទាទោសតាំងពីយូរយារណាស់មកហើយ ,

ដោយយល់ថា អំពើហ្វាស៊ីសដែលពលរដ្ឋខ្មែរបានរងគ្រោះទាំងនេះ គឺពិតជាការចាប់ផ្តើមអនុវត្តនូវផែនការធំទូលាយ ដែលចក្រពត្តិអាមេរិក-វៀតណាមព្រៃនគរបានគាត់តែងឡើងនៅដាឡាត់ ហើយយកទៅសំរិតសំរាំងនៅហូណូលូលូ ដើម្បីនឹងធ្វើសង្គ្រាមរុករានប្រជាជនឥណ្ឌូចិនទាំងមូលឡើងវិញ ដូចមានការវាយលុកព្រមៗគ្នានៅ-ប្រទេសទាំង៣នេះជាកស្តុតាងស្រាប់ : សង្គ្រាមគីមីនៅកម្ពុជា វាយប្រហារប៉ាថេតឡាវនៅលាវវៀង „ម៉ាត់ដុក” នៅឈូងសមុទ្រតុងកឹងនៃវៀតណាមខាងជើង ,

ដោយយល់ថា ផែនការផ្សងព្រេងដ៏ឧក្រិដ្ឋនៃការបង្កសង្គ្រាមរុករានរបស់ចក្រពត្តិអាមេ-រិកនិងរដ្ឋការអាយ៉ងលោកសេរីទាំងប៉ុន្មាននេះ នឹងនាំនូវមហាន្តរាយយ៉ាងលើសលបមកសង្គ្រួបលើពលរដ្ឋនៃអតីតឥណ្ឌូចិន នៃតំបន់អាស៊ីអគ្នេយ៍ និងសាកលលោកថែមទៀតផង ព្រោះវាបង្កើតនូវលទ្ធភាពនៃសង្គ្រាមលោកលើកទី ៣ ឲ្យមានច្រើនឡើងៗ ,

មហាសន្និបាតសាមញ្ញប្រចាំឆ្នាំនៃសមាគមសាស្ត្រាចារ្យខ្មែរ ដែលមានបើកសម័យប្រជុំកាលពីថ្ងៃ ៩ សីហា ១៩៦៤ បានសំរេចជាឯកច្ឆន្ទ ◘

ផ្ញើសេចក្តីសំរេចចិត្តនេះថ្វាយអ្នកអង្គម្ចាស់នាយករដ្ឋមន្ត្រីនិងជូនឯកឧត្តមប្រធានរដ្ឋសភា ដើម្បីទូលទ្រង់និងជំរាបឯកឧត្តម អំពីមនោសញ្ចេតនានិងអាកប្បកិរិយារបស់សមាគមសាស្ត្រាចារ្យខ្មែរចំពោះបញ្ហាខាងលើនេះគឺ :

១. បួលកាន់មរណសញ្ញាវិញ្ញាណក្ខន្ធនៃបងប្អូនរួមឈាមដ៏ថ្លៃថ្លារបស់យើង ហើយចែករំលែកនូវសេចក្តីទុក្ខសោករបស់គ្រួសារអ្នករងគ្រោះទាំងប៉ុន្មាននេះ ;

២. គាំទ្រដោយពេញទំហឹង នូវគំនិតផ្តើមរបស់រាជរដ្ឋាភិបាលដែលបានផ្តន្ទា-

ទោសពួកអាមេរិក-ខាញ់ជាទម្ងន់បំផុត ព្រមទាំងផែនការសម្លាប់មនុស្សយ៉ាងព្រៃផ្សៃរបស់ពួកវាដើម្បីនឹងបង្កហេតុរករឿង ហើយបង្កើតនូវគំនុំគុំគួននឹងការសំអប់រវាងប្រជាពលរដ្ឋវៀតណាមនិងខ្មែរក្នុងគោលបំណង "បំបែកដើម្បីត្រួតត្រា"

៣. គាំទ្រដោយពេញទំហឹងនូវសេចក្តីអំពាវនាវរបស់រាជរដ្ឋាភិបាល និងរដ្ឋសភា ដែលពញាក់សាធារណមតិអន្តរជាតិឲ្យចាប់អារម្មណ៍អំពីទម្ងន់នៃអំពើគគ្រោតនេះ ហើយដែលបានទំលាក់ការទទួលខុសត្រូវទាំងស្រុងទៅលើរដ្ឋាភិបាលពេញ្ញយាជិទាំងពីរ – ខាងលើ ទាំងចៅហ្វាយចក្រពត្តិ ទាំងអាយ៉ងរបស់វា ;

៤. គាំទ្រដោយពេញទំហឹងនូវសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ដែលបានឈប់ឱ្យអង្គការសហប្រជាជាតិ បួលមកបាត់បែងវិនិច្ឆ័យរឿងរ៉ាវតាមព្រំដែនរវាងប្រទេសយើងនិងវៀតណាមខាងត្បូងតទៅទៀត ;

៥. ផ្តន្ទាទោសយ៉ាងទម្ងន់បំផុត ដល់ចក្រពត្តិអាមេរិកនិងអាយ៉ងព្រៃនគរ ដែលបានបង្កើតឆាក "ម៉ាត់ដុក" នៅក្នុងឈូងសមុទ្រតុងកឹងដើម្បីនឹងលើកទឹកចិត្តបរិវារ ជាពិសេសអាយ៉ងព្រៃនគរនិងអាយ៉ង "ខ្មែរសេរី" ផង ហើយដើម្បីនឹងបង្កាត់សង្គ្រាមរុករានឥណ្ឌូចិនឡើងវិញផង ។

៦. សំដែងជាថ្មីទៀតនូវការរីភក្តិនិងភក្តីភាពចំពោះរាជបល្ល័ង្ក ចំពោះសម្តេចឪ និងចំពោះព្រះរាជនយោបាយសន្តិភាព អព្យាក្រឹតភាព បង្រួបបង្រួមជាតិ និងវឌ្ឍនភាពរបស់ព្រះអង្គ ហើយសូមប្តេជ្ញាជីវិត តាមព្រះរាជនយោបាយនេះលុះដល់ទីអវសាន ។

ភ្នំពេញ នៅថ្ងៃទី ២០ សីហា ១៩៦៤

សមាជិកគណៈកម្មការនាយក នៃសមាគមសាស្ត្រាចារ្យខ្មែរ

◙ ក្នុងឱកាសដែលសម្តេចឪទ្រង់យាងចូលទៅក្នុងព្រះជន្មគំរប់ ៤៣ ព្រះវស្សានេះ សមាគមយើងបានថ្វាយលិខិតមួយច្បាប់ ដើម្បីនឹងប្រសិទ្ធថ្វាយព្រះអង្គ នូវពរសព្វសាធុការ បំរើនព្រះជន្មព្រះអង្គឲ្យបានយូរអង្វែងតទៅ ដើម្បីព្រះអង្គទ្រង់បានជាម្លប់ការពារកោះសន្តិភាព ចំពោះការបៀតបៀននៃចក្រពត្តិអាមេរិកាំង នឹងបរិវារព្រៃនគរ-បាងកក ព្រមទាំងពួក “ខ្មែរសេរី„ ដែលមានអាសារី-ឋាន់-សុងសាក់ នឹងបក្សពួកវាជាមេ ។

# សេចក្តីថ្វាយព្រះពរសព្វសាធុការ
# នៃសមាគមសាស្ត្រាចារ្យខ្មែរ
# ក្នុងឱកាសពិធីបំរើនព្រះជន្ម គំរប់ ៤៣ ព្រះវស្សា នៃសម្តេចឪ

**សូមព្រះតេជៈតំកល់លើត្បូង**

**សូមក្រាបបង្គំទូលថ្វាយសម្តេចឪ**

**សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ**

*នៅឱកាសប្រកបដោយនក្ខត្តឫក្សនៃពិធីបំរើនព្រះជន្មព្រះអង្គគំរប់ ៤៣ ព្រះវស្សានេះ ខ្ញុំព្រះបង្គំទាំងឡាយ ជាសមាជិកគណៈកម្មាធិការនាយក នៃសមាគមសាស្ត្រាចារ្យខ្មែរ តំណាងសាស្ត្រាចារ្យប្រាំបីរយនាក់ជាសមាជិក*

*សូមព្រះរាជទានឱកាសប្រសិទ្ធនូវពរសព្វសាធុការ ដ៏វិសេសវិសាលថ្លៃថ្លាអនេកអនន្តថ្វាយព្រះអង្គ សូមព្រះអង្គមានព្រះជន្មយឺនយូរពាន់រយព្រះវស្សា ហើយទ្រង់ស្ថិតនៅតែក្នុងព្រះសុខុមាលភាពដ៏ប្រណីតប្រកបដោយព្រះសុខភាពដ៏បរិបូណ៌ ដើម្បីបានជាម្លប់ដ៏ត្រជាក់ត្រជុំគ្រប់គ្រង់កូនចៅព្រះអង្គទាំងប្រាំមួយលាននាក់ ឲ្យបានបិតថេរនៅលើកោះសន្តិភាពនេះ ព្រមទាំងជាព្រះអគ្គមគ្គុទ្ទេសក៍ បណ្តុះបណ្តាលសម្បូរណភាពនៅលើកោះនេះផង ។*

*ព្រះអង្គគឺពិតជាទិម្នាថនិកដ៏ឈ្លាសវៃក្លៀវក្លា ប្រកបដោយព្រះគតិបណ្ឌិត ជាហេតុដែលនាំឲ្យព្រះអង្គទ្រង់ប្រមូលបាននូវលក្ខណសម្បត្តិគ្រប់បែបយ៉ាង ដើម្បីនឹងបំពេញព្រះកិច្ចដ៏លំបាកនេះ គោលគឺកិច្ចការការពារកោះសន្តិភាពនឹងធ្វើឲ្យកោះនេះបានចំ-*

ចំរុងចំរើនទៅដល់ឋានៈ«ល្អតលាស់»ក្នុងគ្រប់វិស័យ ។

ចំពោះការឃោសនាមួលបង្កាច់ព្រះកិត្យានុភាពនៃព្រះរាជហឫទ័យព្រះអង្គ ហើយនឹងសកម្មភាពវិទ្ធង្សនារបស់ពួក «ខ្មែរសេរី» ដែលមានអាក្សត់សារ-ថាន់-សុនសាក់ជាមេ នឹងរបស់ពួកចក្រពត្តិអាមេរិកាំង-ខាញ់-ឌឹមជាចៅហ្វាយការ ដែលមានគោលបំណងយ៉ាងជាក់លាក់នឹងវាយរំលំនយោបាយឯករាជ្យអព្យាក្រឹតភាព សន្តិភាព របស់ព្រះអង្គនិងប្រជាជាតិខ្មែរនោះ ទូលព្រះបង្គំទាំងឡាយ បានបដិសេធចោលជាអសារបង់តាំងពីដើមទីមកម្លេះ ហើយបានកាត់ទោសពួកឧក្រិដ្ឋទាំងនេះរួចស្រេចទៅហើយ ។

ទូលព្រះបង្គំទាំងឡាយ សូមបួងសួងជាថ្មីម្តងទៀតដល់ទេព្ដាសព្វលោកជាតុមានទេវតារក្សាស្វេតច្ឆត្រជាដើម សូមផ្សព្វផ្សាយនូវព្រះតេជានុភាព ចំរើនព្រះជន្មព្រះអង្គឲ្យបានយឺនយូរ រាប់រយព្រះវស្សា ហើយសូមរក្សាការពារព្រះអង្គជាដរាបតរៀងទៅ ។

ជាថ្មីម្តងទៀត ទូលព្រះបង្គំទាំងឡាយ សូមសំដែងភក្តីភាពដ៏បរិសុទ្ធរបស់ខ្លួនចំពោះព្រះអង្គនិងនយោបាយព្រះអង្គ ហើយសូមប្តេជ្ញាដង្ហែ តាមព្រះអង្គ និងនយោបាយនេះ លុះដល់ទីអវសាន ។ ក្រាបបង្គំទូលថ្វាយ

ភ្នំពេញ នៅថ្ងៃទី ២៧ តុលា ១៩៦៤

ទូលព្រះបង្គំទាំងឡាយជាសមាជិក គណៈកម្មាធិការនាយក នៃសមាគមសាស្ត្រាចារ្យខ្មែរ

សូមមិត្តអានសៀវភៅ

«អ្នកយល់ការណ៍»

ជំហានទី១ឆ្ពោះទៅកាន់វិជ្ជាហ្វីហ្ស៊ិក

**notions élémentaires de physique**

របស់លោក អាំង យារ

សៀវភៅរូបវិទ្យា ជាភាសាជាតិ ដែលមានចេញជាលើកទី២ បន្ទាប់

ពីការផ្សាយរបស់ពុទ្ធិកវិទ្យាល័យមក ។

◙ ដូចអស់មិត្តបានជ្រាប កាលពីថ្ងៃ ២០ តុលានេះ ជនរួមជាតិយើងមានសេចក្ដីឈឺចាប់ជាទំងន់ ដោយចក្រពត្តិអាមេរិកាំងនឹងអាំកញ្ជះវៀតណាមខាងត្បូងរបស់វា បានទំលាក់គ្រាប់បែកលើភូមិអន្លង់ក្រិះ (កំពង់ចាម) ធ្វើឲ្យបងប្អូនយើងបាត់បង់ជីវិតអស់៨នាក់ របួសជាច្រើននាក់ ហើយខូចខាតទ្រព្យសម្បត្តិនឹងដំណាំដាំដុះអស់ជាច្រើនទៀត ។ រលកកំហឹងមួយដ៏មហិមាក៏បានឆេះឆាបឡើង ទូទាំងប្រទេស ។ ក្នុងឱកាសនោះសមាគមយើងបានផ្ញើញត្តិ ១ ច្បាប់ថ្វាយសម្ដេចឪ ដើម្បីសុំអង្វរព្រះអង្គឲ្យទ្រង់បំពេញព្រះភារៈជាព្រះប្រមុខរដ្ឋតទៅទៀត ហើយដើម្បីឧបត្ថម្ភវិធានការទាំងឡាយនៃក្រុមប្រឹក្សាព្រះរាជសម្បត្តិនឹងសភាទាំងពីរ ព្រមទាំងរាជរដ្ឋាភិបាល ។

## ញត្តិនៃសមាគមសាស្ត្រាចារ្យខ្មែរ

**សូមក្រាបបង្គំទូលថ្វាយ**

**សម្ដេចព្រះប្រមុខរដ្ឋ ព្រះបិតាឯករាជ្យជាតិ**

**សូមទ្រង់ជ្រាបក្រោមលម្អងធូលីព្រះបាទ**

*ដោយបានស្ដាប់ព្រះរាជសន្ទរកថា ដែលព្រះអង្គបានសព្វព្រះរាជហឫទ័យប្រោសប្រទានដល់កូនចៅព្រះអង្គក្នុងឱកាសនៃរាជទស្សនកិច្ចពេលថ្មីៗនេះ ក្នុងខេត្តកំពង់ធំនឹងកំពង់ចាម*

*ដោយបានដំណឹងតាមវិទ្យុជាតិ ជាពិសេសតាមសម្ភាសន៍ដែលក្រុមវិទ្យុជាតិបានធ្វើក្នុងឱកាសដ៏ខ្លោចផ្សានៃព្រឹត្តិការណ៍ភូមិអន្លង់ក្រិះមក*

*នឹងដោយបានស្ដាប់សេចក្ដីថ្លែងការណ៍រួមនៃសភាទាំងពីរនឹងព្រះរាជរដ្ឋាភិបាលចុះថ្ងៃ ២៧ តុលា ១៩៦៤ មក*

*ទូលព្រះបង្គំទាំងឡាយជាសមាជិកគណៈកម្មាធិការនាយកនៃសមាគមសាស្ត្រាចារ្យខ្មែរ*

*— បានឃើញកាន់តែច្បាស់ថែមទៀតដូចតែប្រជាជាតិខ្មែរទាំងមូលដែរថា ប្រវត្តិនៃប្រទេសកម្ពុជាសម័យថ្មី គឺជាប្រវត្តិនៃពលរដ្ឋខ្មែរទាំងប្រាំមួយលាននាក់ដែលប្រកបទៅដោយសាមគ្គីភាពយ៉ាងជិតស្និទ្ធជុំវិញព្រះរាជបល្ល័ង្ក អាស្រ័យព្រះអគ្គមគ្គុទ្ទេសក៍ដ៏ភ្លឺ*

ស្វាន និងអង់អាច ហើយប្រកបទៅដោយវីរភាពជាបុត្រដំបូងនៃស្ថាបនករប្រាសាទអង្គរ កំពុងធ្វើពលិកម្មបត្ថែបយ៉ាង ដើម្បីនឹងស្ថាបនាប្រទេសជាតិម្យ៉ាង ហើយម្យ៉ាងទៀត ដើម្បីនឹងការពារឯករាជ្យ អព្យាក្រឹតភាព និងអធិបតេយ្យភាពនៃដែនដីរបស់ខ្លួនប្រឆាំងទល់នឹងអំពើឈ្លានពាននៃចក្រពត្តិអាមេរិកាំង នៃរដ្ឋការនិងពួកប្រតិកិរិយាព្រៃនគរនិងបាងកក ហើយនិងខ្មែរសេរីជាបរិវារដែលមានជនក្បត់ជាតិ សារី-ថាន-សុន សាក់ ជាមេដឹកនាំ។ — ក្នុងរយៈដប់ឆ្នាំនេះ កូនចៅព្រះអង្គក្រោមព្រះបញ្ញាញាណដ៏ពន់វៃនៃព្រះបិតាខ្លួនបានសំរេចនូវសមិទ្ធិសំខាន់ៗច្រើនឥតគណនាមិនអាចប្រៀបធៀបនឹងការងារនៃអាណានិគមនិយមបារាំងក្នុងមួយសតវត្សបានឡើយ។ - ប៉ុន្តែក្នុងរយៈពេលដប់ឆ្នាំនេះ

ចក្រពត្តិនិយមដែលមានចក្រពត្តិនិយមអាមេរិកាំងជាមេ និងបរិវារទាំងក្រៅទាំងក្នុងស្រុកខ្មែរ បានខិតខំប្រើឧបាយកលគ្រប់បែបយ៉ាងដើម្បីនឹងបញ្ឆេះកោះសន្តិភាពទៅក្នុងសៃវៀននៃសង្គ្រាមរុករានរបស់វា ។ អំពើឧក្រិដ្ឋទាំងឡាយរបស់ពួកវាមិនអាចនឹងរាប់ឲ្យបានអស់ទេ ប្រសិនបើមិនរាប់តែអំពើសំខាន់ៗ ដូចជារដ្ឋប្រហារដោយឈួន គ្រាប់បែកបាស់ទិចក្នុងព្រះបរមរាជវាំង គ្រាប់បែកតាមផ្លូវពោធិចិនតុង សង្គ្រាមគីមី ការព្យាបាទព្រះជន្មសម្ដេចឪនៅមេមត់ និងការប្រហារជីវិតនៃបងប្អូនរួមឈាមនៅភូមិចន្ទ្រា និងភូមិអន្លង់ក្រិះក្នុងពេលថ្មីៗនេះជាដើម ។

— បានឃើញកាន់តែច្បាស់ថែមទៀតថា ការព្យាបាទជីវិតនៃបងប្អូនដ៏សុខសាន្តនៅភូមិអន្លង់ក្រិះនេះគ្រាន់តែជាការចាប់ផ្ដើមអនុវត្តន៍ផែនការរុករានប្រទេសកម្ពុជារបស់អ្នកបង្កសង្គ្រាមមាកណាម៉ារ ដែលតែងតែបោកបញ្ឆោតមតិអន្តរជាតិយូរមកហើយថា «ប្រទេសកម្ពុជាជាជំរកនៃពួកវៀតកុង» ។ ចក្រពត្តិអាមេរិកាំង-ខាញ់ដែលបានចាប់ផ្ដើមបង្កាត់ភ្លើងសង្គ្រាមរុករានអយុត្តិធម៌ឡើងនេះ មុខជាមិនផ្សងព្រេងក្នុងភ្លើងនេះជាមិនខាន ប្រសិនបើមានការប្ដេជ្ញាប្រឆាំងតបវិញយ៉ាងម៉ឺងម៉ាត់ពីសំណាក់ពលរដ្ឋខ្មែរក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់នៃសម្ដេចឪនិងពីសំណាក់ប្រជាជនជាមិត្តនៃប្រទេសកម្ពុជា។

ក្នុងកាលៈទេសៈដ៏ធ្ងន់ធ្ងរនេះ ដើម្បីនឹងកាត់ដៃប្រឡាក់ឈាមនៃចក្រពត្តិអាមេ-រិកាំង-ខាញ់ ប្រយោជន៍នឹងការពារអធិបតេយ្យភាពនិងដែនដី

ក. ទូលព្រះបង្គំទាំងឡាយយល់ឃើញថា សាមគ្គីភាពនៃប្រជាជាតិជុំវិញព្រះរាជបល្ល័ង្កគាន់តែជាការចាំបាច់ សាមគ្គីភាពជុំវិញសម្តេចឪគាន់តែជាការចាំបាច់ ហើយវត្តមាននៃសម្តេចឪនៅបន្តូតកម្ពុជាគាន់តែជាការចាំបាច់ថែមទៀតជាងពេលណាៗ ទាំងអស់ ។

ដូច្នេះ ទូលព្រះបង្គំទាំងឡាយសូមឧបត្ថម្ភទាំងស្រុងនូវសេចក្តីសំរេចចិត្តនៃក្រុមប្រឹក្សាព្រះរាជសម្បត្តិ ដែលបានសង្កេតថាកាលៈទេសៈសព្វថ្ងៃនេះគ្មានការចាំបាច់នឹងជ្រើសរើសព្រះរាជាទាល់តែសោះ ហើយដែលបានបញ្ជាក់ជាឯកច្ឆន្ទ កាលពីថ្ងៃ២៧តុលា ១៩៦៤ថា ទទួលស្គាល់តែសម្តេចឪមួយព្រះអង្គប៉ុណ្ណោះជាព្រះអគ្គមគ្គុទ្ទេសក៍ជាតិ ។ ចំណែកឯសេចក្តីមួលបង្កាច់របស់គណការខ្មែរសេរីខ្ញុំកញ្ជះអាមេរិកាំងវិញ ទូលព្រះបង្គំទាំងឡាយនឹងប្រជាជាតិទាំងមូលបានបដិសេធចោលជាឥតសារបង់តាំងតែពីដើមរៀងមកម្ល៉េះៗ

១. ទូលព្រះបង្គំទាំងឡាយ សូមឧបត្ថម្ភទាំងស្រុងនូវសេចក្តីថ្លែងការណ៍រួមនៃសភាទាំងពីរ នឹងរាជរដ្ឋាភិបាល ដែលបានឲ្យសេចក្តីព្រមានជាមុនក្រោយបង្អស់ដល់ពួកចក្រពត្តិអាមេរិកាំង-វៀតណាមខាងត្បូងថា ប្រសិនបើពួកវាហ៊ានតែរុករានប្រទេសកម្ពុជាម្តងទៀត

១. «កងខេមរភូមិន្ទនឹងប្រឆាំងតបតវិញភ្លាម» ពីព្រោះចក្រពត្តិស្តាប់បានតែភាសាអាវុធប៉ុណ្ណោះ ។

២. ប្រទេសកម្ពុជានឹងផ្តាច់ចំណងទូតពីសហរដ្ឋអាមេរិកជាបន្ទាន់

៣. ហើយប្រទេសកម្ពុជានឹងទទួលស្គាល់ដោយពេញលក្ខណៈច្បាប់នូវរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ហើយនឹងរណសិរ្សជាតិរំដោះ

វៀតណាមខាងត្បូង ដែលទុកជាអ្នកតំណាងតែមួយនៃប្រជាជនវៀតណាមខាងត្បូង ។

គ. ហើយទូលព្រះបង្គំទាំងឡាយ សូមឆ្លៀតឱកាសនេះសំដែងជាថ្មីម្ដងទៀតនូវសេចក្ដីស្វាមីភក្ដិដ៏សុទ្ធសាធរបស់ខ្លួន ចំពោះព្រះរាជបល្ល័ង្កដែលមានសម្ដេចព្រះមហាក្សត្រិយានីជាព្រះនិមិត្តរូប ចំពោះព្រះអង្គសម្ដេចឪ និងចំពោះព្រះរាជនយោបាយសន្តិភាព អព្យាក្រឹតភាព សាមគ្គីភាព និងវឌ្ឍនភាពរបស់ព្រះអង្គ ហើយសូមប្ដេជ្ញាដង្ហែតាមព្រះរាជនយោបាយនេះលុះដល់ទីអវសាន ។

សេចក្ដីគួរពុំគួរសូមទ្រង់ព្រះមេត្តាប្រោស
សូមក្រាបបង្គំទូលថ្វាយ
ភ្នំពេញ នៅថ្ងៃទី ១ វិច្ឆិកា ១៩៦៤
ទូលព្រះបង្គំទាំងឡាយ ជាសមាជិកនៃគណៈកម្មាធិការនាយក សមាគមសាស្ត្រាចារ្យខ្មែរ

★

▣ ក្នុងឱកាសដែលសម្ដេចព្រះពោធិវង្សបានទទួលព្រះកេតនភណ្ឌជាសម្ដេច សមាគមសាស្ត្រាចារ្យយើង ដើម្បីនឹងសំដែងនូវសេចក្ដីសោមនស្សសាទរនឹងសេចក្ដីស្នេហារបស់ខ្លួនចំពោះព្រះអង្គ បានផ្ញើលិខិតនេះប្រគេនព្រះអង្គ ។

សមាគមសាស្ត្រាចារ្យខ្មែរ
លេខ ១២៣E វិថីព្រះសីហនុ
ភ្នំពេញ

ភ្នំពេញ ថ្ងៃទី ១២ សីហា ១៩៦៤

សូមនមស្ការចំពោះសម្ដេចព្រះពោធិវង្សអគ្គធិការពុទ្ធិកសិក្សានៃព្រះរាជអាណាចក្រ សូមមេត្តាជ្រាប ។

សម្ដេចជាទីគោរព ក្នុងឱកាសដ៏នក្ខត្តឫក្ស ដែលព្រះអង្គបានទទួលនូវព្រះកេតនភណ្ឌជាសម្ដេចនេះ

ខ្ញុំព្រះករុណាទាំងឡាយជាសមាជិកគណៈកម្មាធិការនាយកនៃសមាគមសាស្ត្រាចារ្យខ្មែរ តាងនាមសមាជិកខ្លួនទាំងប្រាំបីរយនាក់ មានកិត្តិយសនឹងសេចក្ដីរីករាយជាពន់ពេក និងសូមប្រគេនព្រះអង្គនូវសេចក្ដីសោមនស្សសាទររបស់ខ្លួនដោយអស់ពីដួងចិត្ត ។

ក្នុងឱកាសនេះ ខ្ញុំព្រះករុណាទាំងឡាយសូមប្រសិទ្ធប្រគេនព្រះអង្គនូវពរមហាជាគ...

ជ័យសិរីមង្គលវិបុលសុខ សូមព្រះអង្គមានព្រះជន្មាយុយឺនយូរពេញជាងរយព្រះវស្សា ដើម្បី ព្រះអង្គផ្តល់នូវវិភាគទានសំខាន់ៗដល់ពលរដ្ឋយើងក្នុងការឧបត្ថម្ភព្រះពុទ្ធសាសនា ក្នុង ការគ្រាប់លើមាគ៌ាបង្រួបបង្រួមជាតិឆ្ពោះទៅរកវឌ្ឍនភាពដូចជាអារ្យប្រទេសនានា ។

សេចក្តីគួរពុំគួរ សូមព្រះមេត្តាប្រោស

▣ ចំពោះលិខិតនេះ សម្តេចព្រះពោធិវង្សទ្រង់បានឆ្លើយតបមកយើងវិញដូចតទៅ ៖

★

អគ្គាធិការដ្ឋាន នៃពុទ្ធិកសិក្សា

លេខ ១៣៥

ព្រះរាជាណាចក្រកម្ពុជា

ភ្នំពេញ ថ្ងៃទី ២១ សីហា គ.ស. ១៩៦៤

សម្តេចព្រះ ពោធិវង្ស អគ្គាធិការ នៃ ពុទ្ធិកសិក្សា

សូមចំរើនពរមកលោកជាគណៈកម្មាធិការនាយក នៃសមាគមសាស្ត្រាចារ្យខ្មែរ

សូមជ្រាប ។

លិខិតរបស់លោកចប្លាប់ ចុះថ្ងៃទី១៤សីហា១៩៦៤ ដែលមានសេចក្តីសរសើរ ប្រកបដោយសោមនស្សព្រមទាំងប្រសិទ្ធិពរសព្ទសាធុការចំពោះរូបអាត្មា ដែលទើបនឹង បានទទួលនូវសមណសក្តិជាទីសម្តេចក្នុងពេលថ្មីៗនេះ នាំឲ្យអាត្មាមានសេចក្តីរីករាយ យ៉ាងក្រៃលែង ។

អាត្មាភាពសូមថ្លែងនូវអំណរគុណចំពោះអស់លោកជាសមាជិកនៃគណៈកម្មាធិ-ការនាយកនៃសមាគមសាស្ត្រាចារ្យខ្មែរ ដែលជាតំណាងនាមសមាជិកទាំងប្រាំបីរយនាក់ ហើយសូមប្រសិទ្ធិពរសព្ទសាធុការជូនអស់លោកវិញ សូមឲ្យបានប្រកបដោយសុខ សួស្តីជ័យមង្គលគ្រប់ប្រការអស់កាលជានិច្ចនិរន្តរ៍តរៀងទៅ ។

សម្តេចព្រះពោធិវង្ស

## ◙ ពិធីជប់លៀងជាកិត្តិយសដល់មិត្ត គួច គៅសា

ដូចមិត្តបានជ្រាបស្រាប់ មិត្ត គួច គៅសា បានព្រះរាជរដ្ឋាភិបាលយើងជ្រើសរើសឲ្យទៅបង្រៀនភាសាខ្មែរ នៅសាកលវិទ្យាល័យ ភាសាបរទេសនៅប៉េកាំង ។ មិត្តគៅសា បានចេញដំណើរទៅកាលពីវិស្សមកាលមុននេះ ។



មិត្តសមាជិកនៃគណៈកម្មាធិការនាយក ហើយនិងមិត្តឯទៀតៗនៅភ្នំពេញក្តី ឬដែលមកកំសាន្តនៅភ្នំពេញក្តីចំនួន៣០នាក់ បាននាំគ្នារៀបចំពិធីជប់លៀងមួយដ៏ស្និទ្ធស្នាលនៅភោជនីយដ្ឋានទូរ៉ូទ្រ័ក្លូតាំង កាលពីថ្ងៃ២៣សីហា ដើម្បីជាកិត្តិយសដល់ការចេញដំណើររបស់មិត្តយើងផង ដើម្បីនឹងពង្រឹងនូវចំណងមេត្រីភាពរបស់យើងផង (ភាគទានផ្ទាល់ខ្លួន) ។

មិត្តអ៊ឹង គឹមសេង និង គឹម ស៊ីយ៉ុនដែល ត្រូវផ្លាស់ទៅបង្រៀននៅអនុវិទ្យាល័យ "ព្រះរាជបូជនីយកិច្ចដើម្បីឯករាជ្យស៊ីនុវ៉ែត្រង", និងទៅធ្វើតាងហ្វាងនៅអនុវិទ្យាល័យតាំងគោកកំពង់ធំ ក៏បានត្រូវអញ្ជើញមករួបរួមដែរ ។ ពិធីបានប្រព្រឹត្តទៅក្នុងបរិយាកាសដ៏រីករាយនិងស្និទ្ធស្នាល ។

## ▣ការក្រាបបង្គំលា នឹង ការចេញដំណើរ

ពីរថ្ងៃមុនចេញដំណើរមិត្ត តៅសា ដោយមានមិត្ត ទីវ អ៊ុល ជូនផងបានទៅក្រាបថ្វាយបង្គំលាសម្តេចព្រះសំឃរាជថ្នាក់ទី១ ដែលព្រះអង្គធ្លាប់តែប្រោសប្រណីរាប់អានសមាគមយើងជាខ្លាំង ។ ប៉ុន្តែការទៅក្រាបថ្វាយបង្គំនៅពេលនោះ(២៦-៨-៦៤) មានគោលបំណងធំមួយទៀតគឺសាកសួរព្រះសុខភាពព្រះអង្គដែលបានប្រសើរឡើងគ្រាន់បើហើយ ។

បានចេញទៅជូនមិត្ត តៅសា ឡើងយន្តហោះក្រុមហ៊ុន CPA ថ្ងៃ ២៧-៨-៦៤ ម៉ោង ១៦,១០)មាន គ្រួសារហើយនឹង មិត្តភក្តិជិតស្និទ្ធជា ច្រើនជាអាទិ៍មានមិត្ត អ៊ុល ចន្ទ ឌួរ ធុន លោក អ៊ិត ហេង



ម៉ែនប៉ៃណា តឹកគឹមអ៊ុន, ទីវ អ៊ុល, កង តឹកហ៊ុយ នឹង ជា ចេង ។

▣


**សូមមិត្តអានឯកសារសំខាន់មួយ:**

«ទស្សនាវដ្តីគ្រូបង្រៀន» លេខពិសេស ស្តីពី សហករណ៍សិក្សា

របស់សមាគម បុគ្គលិក សិក្សាខ្មែរ ( AMCEK )

សូមសរសេរទៅមិត្ត ពាន់ អឹម ទីចាត់ការកិច្ចការគរុកោសល្យ, ភ ៣

# យើងឆ្លើយឆ្លងគ្នា



ពីពេលមុន យើងបានទទួលអត្ថបទ "សព្ទខ្មែរ" មួយស្តីពីពាក្យដែលទាក់ទងនឹងចំណែកផ្សេងៗនៃខ្លួនមនុស្ស ទ.បានមាត់ មាត់អើល ។ សូមមិត្តដែលបានផ្ញើអត្ថបទនេះ មកយើងពីពេលមុន មេត្តាផ្ញើមកយើងម្តងទៀតៗអរគុណៗ

▣ មិត្ត ឡុប ផ្លែង វិទ្យាល័យព្រះស៊ីសុវត្ថិ

អត្ថបទរបស់មិត្ត "ឫសគល់នៃពាក្យខ្មែរ" យើងបានទទួលហើយ ហើយសូមសរសើរសេចក្តីព្យាយាមរបស់មិត្ត ក្នុងការស្រាវជ្រាវ ។ យើងស្តាយដោយមិនអាចចុះក្នុងលេខនេះបាន ពីព្រោះរោងពុម្ពមានការយឺតយ៉ាវជាពន់ពេក ដូចមិត្តឃើញស្រាប់ ។

▣ មិត្ត គឹម សុនទ្រិញ វិទ្យាល័យព្រះស៊ីសុវត្ថិ

យើងបានពិនិត្យអត្ថបទរបស់មិត្ត « ការប្រើពាក្យនឹងសូរសព្ទ » រួចហើយ ប៉ុន្តែស្តាយដោយមិត្តទាំងឡាយពុំអាចនឹងអានអត្ថបទរបស់មិត្តបានក្នុងលេខនេះ មកពីហេតុដូចយើងបានជំរាបមិត្ត ឡុប ផ្លែង រួចហើយ ។

▣ មិត្ត យី យង់ តំណាងអនុវិទ្យាល័យសន្តិភាព

សូមថ្លែងអំណរគុណដល់មិត្ត ដែលមានសុឆន្ទៈនឹងឆ្លើយតបនឹងសេចក្តីអំពាវនាវរបស់យើង ដោយផ្តល់ដំណឹងសុខទុក្ខនៃមិត្តសមាជិកក្នុងសាលាមិត្ត មកយើងយ៉ាងឆាប់រហ័ស ។ យើងនឹងផ្សាយដំណឹងនេះនៅក្នុងលេខនេះ ។

សូមប្រសិទ្ធពរសព្ទសាធុការជូនមិត្ត ពន់ឌី បំរើន កេសុកមង្គល យ៉ាងគ្រប់គ្រាន់ឃើញនៅក្នុងផ្លូវនៃជីវភាពថ្មីដែលមិត្តទើបនឹងបាកសាងកាលពីថ្ងៃពិវាហ៍កានេះ ។

## មិត្ត ហ្វូ ប៊ុនប៉ៃ វិទ្យាល័យបោពញ្ញាយ៉ាត

សូមសរសើរចំពោះសកម្មភាពរបស់មិត្ត ដែលបានបំពេញការៈជាតំណាង (នៃអនុវិទ្យាល័យបច្ចេកទេសក្នុងពេលមុន)យ៉ាងដិតដល់: ប្រមូលកាតតាន យ៉ាងទៀងទាត់មួយខែម្ដងៗ ផ្ដល់ពត៌មានអំពីសុខទុក្ខរបស់មិត្តទាំងឡាយ ស្នើឲ្យរកតំណាងជំនួសមិត្ត ប្រគល់កិច្ចការទៅគណៈកម្មាធិការខេត្ត ។ សូមមិត្តជ្រាបថា តំណាងថ្មីគឺមិត្ត ប៊ុល សារេត តាងហ្វាង ។

## មិត្ត ជឹម ស៊ុនលី អនុវិទ្យាល័យត្រាំកក់

សូមមិត្តអញ្ជើញទៅកាន់តំបន់ថ្មីឲ្យបានសុខចំរើន ។ ចំណែកឯសេចក្តីស្នើរបស់មិត្តថាយកមិត្ត ប្រាក់ សុង ជាតំណាងជំនួសមិត្តនោះ យើងយល់ព្រមហើយ ។ មិត្ត ប្រាក់ សុង តាំងពីដើមរៀងមក ហើយពិសេស ចាប់តាំងពីកាន់តំណែងថ្មីមក បានបំពេញការៈយ៉ាងសកម្ម ដូចមានមកជូនដំណឹងគណៈកម្មាធិការនាយកផ្ទាល់មាត់ពីការដែលមិត្តត្រា គឹម សុន ចូលគេងពេទ្យជាដើម។ សូមសរសើរមិត្ត ប្រាក់ សុង។ សូមមិត្ត សុង ឲ្យដំណឹងយើងអំពីស្ថានភាពរោគរបស់មិត្ត គឹម សុន ផង ។

## មិត្តត្រា គឹមសុន អនុវិទ្យាល័យព្រះសោមា

ក្រោយពីបានទទួលដំណឹង តាមមិត្ត ប្រាក់ សុងភ្លាមមក យើងជូនដំណឹងដល់មិត្តក្នុងគណៈកម្មាធិការនាយកភ្លាម ។ ហើយប៉ុន្មានថ្ងៃក្រោយមក លុះមិត្តខ្លះទៅសួរឯមន្ទីរពេទ្យ ក៏ឃើញថាមិត្តចេញផុតមកហើយ ។ សូមមិត្តអភ័យទោសចំពោះការយឺតយ៉ាវដោយអចេតនានេះ ។

សូមប្រសិទ្ធពរសព្ទសាធុការជូនមិត្តបានជាសះស្បើយឆាប់ហ័ស !

យើងឆ្លើយឆ្លងគ្នា....... ត

■ មិត្ត លី គឹមអ៊ី តំណាងអនុវិទ្យាល័យទេពប្រណម្យ

*សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមិត្តគឹម ហុក ដែលបានពណ៌នាអំពីបរិយាកាសជប់លៀងមុនបវេសនកាល ប្រាប់យើងយ៉ាងក្បោះក្បាយ ។*

*សូមថ្លែងអំណរគុណនិងសេចក្ដីសរសើរចំពោះមិត្ត គឹមអ៊ី ដែលបានបំពេញភារៈនិងណែនាំឲ្យបំពេញភារៈយ៉ាងសកម្ម ក្នុងបំណងសាមគ្គីភាពនៃបុគ្គលិកនិងក្នុងបំណងនៃការរីកលូតលាស់សិក្សាធិការយើង ។*

■ មិត្តសេង ប៊ុនថិន តំណាងអនុវិទ្យាល័យសាលាលេខ ៥

*យើងបានពិនិត្យអត្ថបទរបស់មិត្ត «ព្រះរាជនយោបាយកែទម្រង់សិក្សា» ហើយនិងកំណាព្យ «ឯកកជ្ឈទីតរ ......» ព្រមទាំងគំនូររបស់លោក មិន ហេងឃៀង រួចហើយ ។ អត្ថបទទាំងនេះមានសារៈសំខាន់ច្រើន ប៉ុន្តែគំនូរពាស់គ្រន់គួរជាខ្មៅដៃ ។*

■ មិត្តខឹម ត្រាណ និ-សាស្ត្រាចារ្យ-ខ្មែរឆ្នាំទី២

*យើងបានទទួលដោយក្រៀមក្រំនូវដំណឹងមរណភាពនៃលោកឪពុកមិត្ត ដែលយើងសូមរំលែកសេចក្ដីទុក្ខជាភាគរភាព ។*

5

■ សូមមិត្ត ពន្យល់អត្ថប្រយោជន៍នៃសមាគមយើង ដល់មិត្តសាស្ត្រាចារ្យឯទៀតៗ ហើយអញ្ជើញលោកចូលជាសមាជិក ។

■ សូមមិត្ត រង់ចាំអានក្នុងលេខក្រោយ នូវមេរៀនប្រវត្តិវិទ្យា ភូមិវិទ្យា រូបវិទ្យា និងគណិតវិទ្យា ជាភាសាខ្មែរ ។

■ សូមមិត្ត អានទស្សនាវដ្ដីឲ្យចប់ ហើយជួយយោបល់ផង ។




# ប្រធានវិញ្ញាសា

## នៃការប្រឡងប្រជែង ជ្រើសរើសនិស្សិត-សាស្ត្រាចារ្យ

(សម័យប្រឡង ១៨ កញ្ញា ១៩៦៤)

O

## វិញ្ញាសា សាកល្បងសំរាប់បេក្ខជន ដែលត្រូវសិក្សា ឆ្នាំទី២ (២ម៉ោង)

I. —Traduire en cambodgien le texte suivant:

Le thème fondamental des trois éducations

(Emile de J.J. Rousseau)

Nous naissons faibles, nous avons besoin de force; nous naissons dépourvus de tout, nous avons besoin d'assistance; nous naissons stupides, nous avons de jugement. Tout ce que nous n'avons pas à notre naissance et dont nous avons bien étant grand, nous est donné par l'éducation.

Notre éducation nous vient de la nature ou des hommes ou des choses. Le développement interne de nos facultés et nos organes est l'éducation de la nature; l'usage qu'on nous apprend à faire de ce développement est l'éducation des hommes; et l'acquis de notre propre expérience sur les objets qui affectent est l'éducation des choses.

Chacun de nous est donc formé trois par sortes de maîtres. Le disciple dans lequel leurs diverses leçons se contrarient est mal élevé, et ne serait jamais d'accord avec lui-même; celui dans lequel elles tombent toutes sur les mêmes points, et tendent aux mêmes fins, va seul à son but et vit conséquemment. Celui-là est bien élevé.

II- — ចូរអ្នកអធិប្បាយអំពីផលប្រយោជន៍នៃការអប់រំក្នុងជីវភាពមនុស្ស ។

# ប្រធានដូចគ្នាសំរាប់គ្រប់វិជ្ជាជ្រើសរើស

## វប្បធម៌ទូទៅ

តើការចេះដឹងខាងប្រវត្តិសាស្ត្រមានប្រយោជន៍អ្វីខ្លះដល់មនុស្សឯទៀត ក្រៅពីអ្នកបច្ចេកទេស និង សាស្ត្រាចារ្យ ខាងវិជ្ជានេះ ។

■

# វិជ្ជាជ្រើសរើស ភាសាខ្មែរ

## ១- វិញ្ញាសា **បរមាធិប្បាយខ្មែរ** (៣ ម៉ោង)

**C. E. S. de littérature khmère**

( 24 - 9 - 64 )

ប្រធាន: តើគេអាចសន្មតថា « ប្រសិនបើ ពុំមានភូមិសាស្ត្រ ប្រវត្តិសាស្ត្រ ចិត្តសាស្ត្រ នីតិសាស្ត្រ និងទស្សនវិជ្ជាផងទេ » «អក្សរសាស្ត្រ» នឹងប្រែទៅជាសិល្ប មួយក្នុងពពួកសិល្បៈនានា ដូច្នេះបានដែរឬទេ ។

បើគេសន្មតថានៅក្នុង «អក្សរសាស្ត្រ» គ្មានភូមិសាស្ត្រ គ្មានប្រវត្តិសាស្ត្រ គ្មានចិត្តសាស្ត្រ គ្មាននីតិសាស្ត្រ និងគ្មានទស្សនវិជ្ជាបូលផងទេ អក្សរសាស្ត្រនឹងត្រូវទៅជាសិល្បៈមួយក្នុងចំណោមសិល្បៈនានា គឺត្រូវមានលក្ខណៈខ្លះៗ ឲ្យស្របទៅដូចសិល្ប ទាំងនោះដែរ ។

តាមសេចក្ដីសន្មតខាងលើនេះ ប្អូនអ្នកប្រៀបធៀបរឿង មហាវេស្សន្តរជាតក «របស់លោក ញ៉ុក ថែម» និងរឿង «ទុំទាវ» ។ តើរឿងណាមួយមានសភាពជាអក្សរ-សាស្ត្រជាងគេ ? ពីព្រោះអ្វី ? ។

## ២- វិញ្ញាសា ភាសាបារាំង (៣ ម៉ោង)

Qu' est - ce qu'un homme d'action ? - Esquissez son portrait moral tel que vous le concevez d'après vos impressions personnelles et d'après vos souvenirs littéraires.

# វិជ្ជាជ្រើសរើស ភាសាអង់គ្លេស

## ១ - វិញ្ញាសា អង់គ្លេស ( ៣ម៉ោង )

### HOW TO MAKE TEA

«My time runs short, Dick said. I should like to see at least a part of what we call the underword: the warehouses, workshops, factories, power-houses, kitchens, bakeries, cold storage plants, stables and garages, some of which are right under the building and the rest are connected with it by a network of tiled subways. It's a sight well worth seeing.»

« From what I have seen already, I dare say that man has hardly ever done anything more wonderful than this. You remember the time when we went to school together and read history and were told about the seven wonders of the world... well, by Jove. What's this ? Is it the Grocery Department ? »

They were coming to the Grocery Hall, right in the centre of the Food Section. Joe, in spite of all he had said about groceries, could not help being interested in the way his uncle's trade was carried on, after what he had seen in connection with Furniture and Hosiery.

Dick smiled as he took the grocer's nephew to the demonstration counte r where the two friends were offered - free of charge - a cup of hot fragant tea and a booklet in which Joe could read :

HOW TO MAKE TEA :

1. Scald the tea-pot and drain it completely.
2. Put in one tea-spoonful of tea for each person and « one for the pot »
3. The moment it boils, pour the water on the tea.
4. Allow to stand for three minutes.

I/ Explain :

a/These idioms: «my time runs short», «It's a sight.... seeing»; «He could not help being...was carried on.» ;«free of charge »

b/These words: underworld, power-houses, storage, stables, net-work, counter, fragrant, to scald, to drain, to stand.

II/ Pick up the words in the lesson where« S » is sounded(Z) and the words where «S» is sounded ( S ).

III/Make four sentences with each of the following postpositions, taking care to use transitive and intransitive meanings: up, down, in, out.

IV/Describe a chinese grocery shop.

## ២– វិញ្ញាសា បរមាធិប្បាយបារាំង ( ៣ម៉ោង )

Parce que La Bruyère a prétendu que Corneille peignait les hommes «tels qu'ils devraient être », on en a conclut que son théâtre était invraisemblables.

Pourtant n'exprime t - il pas fidèlement les mœurs et les tendances de la Société de son temps ?

# វិជ្ជាជ្រើសរើស : ភាសាបារាំង

## ១. វិញ្ញាសា បារាំង ( ៣ ម៉ោង )

Expliquez et discutez cette pensée de Michelet: «le Grand Siècle.... c'est le dix-huitième siècle que je veux dire ! » .

## ២ វិញ្ញាសា អង់គ្លេស

### THE JOINER AND CARPENTER

The boys went to see Mr. Pott's new house almost every day. And every day they could notice some progress. The walls rose higher and higher Then the carpenter began making the frame of the roof and laying the floors.

Mr.Wood, the carpenter, was also a joiner. No better or more skilful workman could be found in the whole neighbourhood.

A few days later he began making the doors and the window-frames.

You could often see Dick peeping into the house to see the large dining-room and the still larger drawing-room. The latter room had been turned into a real workshop, all littered with shavings and full of tools of every kind.

And Dick Pry explained to his friend Joe the uses of the plane (for smoothing boards), the chisel ( for cutting holes and groove in the wood ), the auger and the gimlet (for piercing holes).

Of course even Joe knew what a hammer or a saw is used for. Do you ?

But Dick was learning something new every day. He could have. spent his time in a worse and less useful way.

1/ Expliquer en anglais les mots :
Joiner, to peep, latter, shavings, tools, hammer.

2/ Donner le comparatif et le superlatif de :
good, near, rare, sick, bad, pure, late, large, kind, merry, notorious, steady, yellow, inquisitive, silly, gay.

3/ Traduire les adjectifs précédents et faire une phrase en anglais avec chacun d'eux au comparatif et au superlatif.

4/ Traduire les deux premiers paragraphes du texte en français, depuis le commencement jusqu'à..... the whole neighbourhood.

5/ Essay : Describe your own house( à écrire en anglais).

# វិជ្ជាជ្រើសរើស: ប្រវត្តិវិទ្យា-ភូមិវិទ្យា

## ១.២ វិញ្ញាសា ប្រវត្តិវិទ្យា (៣ម៉ោង)

Analysez les grands évènements historipues entre les deux guerres mondiales

## ១.២. វិញ្ញាសា ភូមិវិទ្យា (៣ម៉ោង)

Comparez l'économie du Cambodge avec celle de l'Afrique du Nord et en particulier avec celle de l'Algérie.

▣

# វិជ្ជាជ្រើសរើស គណិតវិទ្យា

## ១ វិញ្ញាសា គណិតវិទ្យា (៣ម៉ោង)

I.— Calculer la hauteur, l'aire totale et le volume d'un tétraèdre régulier d'arête a .

II.— Démontrer que l'hyperbole $\frac{x - m}{mx - 1}$ passe par 2 points fixes A et B .

Lieu du centre de l'hyperbole ?

III.— 1/Calculer l'angle aigu dont la tangente égale le cosinus.

2/Un point M se déplace sur un arc de circonférence AB qui est le quart d'une circonférence. Le rayon est désigné par R, le centre par O l'angle AOM par 2a, la projection de M sur le diamètre OB perpendiculaire à OA par H.

On demande de déterminer a par la condition $AM - HM = R$ .

3/ Quelle est la valeur de a quand la corde AM est tangente au cercle de diamètre OH ? Calculer OH dans cette hypothèse.

Quelle est la valeur de a quand la droite OB est tangente au cercle de diamètre AM?

4/ Etudier les variations de la fonction $Y = AM + HM$, en prenant $X = \sin a$ comme variable indépendante. Construire la courbe représentant ces variations.

## វិជ្ជាជ្រើសរើស គណិតវិទ្យានិងរូបវិទ្យា-គីមី

### ១.២. វិញ្ញាសា រូបវិទ្យា (៣ម៉ោង)

Epreuve : PHYSIQUE Durée : 3 heures

I.— Expliquer les phénomènes d'électrolyse dans une pile formée d'une cathode en zinc plongeant dans une solution de sulfate de zinc et d'une anode en cuivre plongeant dans une solution de sulfate de cuivre.

II.— Dessiner un faisceau de rayons lumineux issu d'un objet à travers une lame à faces parallèles, d'indice n et d'épaisseur e. Quel est le déplacement apparent ? Quel est le sens de ce déplacement par rapport à celui de la lumière ?

III— Deux lampes électriques portent les indications suivantes :

Pour $A_1$ : 110 volts — 40 Watts;

Pour $A_2$ : 220 volts — 100 Watts

1/ Quelles sont, en régime normal, les résistances de ces deux lampes et les intensités qui les traversent ?

2/ Quel est le prix de revient mensuel de huit heures d'éclairage par jour avec chacune des lampes sachant que le prix du kilowatt-heure est de 5 riels ?

3/ On dispose seulement d'une tension de 220 volts et, pour utiliser ces lampes, on songe d'abord à les mettre en série. Calculer quelle serait dans ce cas l'intensité traversant ces lampes, en supposant que leur résistance est invariable. Calculer les tensions aux bornes de chacune d'elles.

Les lampes auront-elles leur aspect normal? Quel est l'accident auquel on doit s'attendre si l'on fait effectivement l'expérience?

4/ On dispose de plusieurs lampes de chacun de ces deux types. Indiquer le shéma suivant lequel on devrait monter $n_1$ lampes de type $A_1$ et $n_2$ lampes de type $A_2$, les lampes de chaque groupe étant en parallèle et les groupes étant en série, pour que, l'ensemble étant alimenté par une tension de 220 volts, les lampes fonctionnent cependant dans les conditions normales. Quelles sont les valeurs minima de $n_1$ et de $n_2$ ?

# វិជ្ជាជ្រើសរើស រូបវិទ្យា-គីមីនិងវិទ្យាសាស្ត្រធម្មជាតិ-គីមី

## ១. វិញ្ញាសា វិទ្យាសាស្ត្រធម្មជាតិ (៣ម៉ោង)

Faire le schéma détaillé et annoté de la partie interne du cœur et indiquer d'un flèche le sens de la circulation du sang.

Etude du tissu sanguin.

## ១.២– វិញ្ញាសា គីមី (៣ម៉ោង)

I.— En appliquant les règles de Berthollet aux mélanges suivants en solution, indiquer s'il se produit ou non des réactions de double décomposition:

$CuSO_4 + NaOH \quad AgNO_3 + CuCl_2 \quad AgNO_3 + Na_2SO_4$

$BaCl_2 + (NH_4)_2SO_4 \quad NH_4Cl + NaOH \quad FeCl_3 + NaOH$

II.— Les oxydes de fer

III.— Lorsqu'on ajoute de la soude à une solution de sulfate d'aluminium $Al_2(SO_4)_3$ ,on observe d'abord un précipité, puis ce précipité se dissout. Expliquer et formuler les réactions qui ont eu lieu.

IV.— On traite une solution d'hydroxyde de zinc par une solution chlorhydrique normale. Ecrire la réaction. Il a fallu 10,50 $cm^3$ de liqueur chlorhydrique pour neutraliser 50 $cm^3$ de la première solution. L'hydroxyde de zinc réagit-il avec la soude? Ecrire la réaction s'il y a lieu.

$Cl = 35,5; \; O = 16; \; Na = 23; \; Zn = 65 \; H = 1$

Calculer le titre de la solution d'hydroxyde de Zn.

◙

សូមមិត្តកែតំរូវដូចតទៅនេះ

( “អត្ថបទ និងឯកសារ„ ទស្ស.ល. 14, ទំព័រ 61 )

| | | |
|---|---|---|
| Afrique | 29. | Dar - es - Salaam |
| | 39. | Port au Prince |
| | 42. | République Dominicaine St - Domingue |
| | 44. | Lima |
| | 45. | San José |
| Asie | 59. | Arabie Saoudite El Riad |
| Europe | 88. | Minsk |

ប្រវត្តិវិទ្យា

# របៀបបោះឆ្នោតជ្រើសរើស

គង់ សុខ

បន្តិចទៀត ប្រមាណជាង១០អាទិត្យទៅមុខនេះ ស.រ.អា នឹងត្រូវបោះឆ្នោតរើសប្រធានាធិបតី ព្រមទាំងអនុប្រធានាធិបតីជាលើកទី ៤៥ ក្រោយដែលប្រទេសចំនួន ១៣ ជាអាណានិគមអង់គ្លេស បានឯករាជ្យហើយមករួបរួមគ្នាក្នុងមហាសធារណរដ្ឋនេះ ។ ថ្ងៃជ្រើសរើស កំណត់ទៅថ្ងៃទី ៣ វិច្ឆិកា ១៩៦៤ ។

នៅស.រ.អា. គេបោះឆ្នោតរើសប្រធានាធិបតីក្នុងរយៈ ៤ ឆ្នាំម្តង ។ របៀបនេះ គេអនុវត្តមកប្រមាណជា២សតវត្សហើយ ។ ឆ្នាំនេះ នៅខែវិច្ឆិកា ប្រជាជនជាង៧០លាននាក់ ទាំងប្រុសទាំងស្រីនឹងត្រូវបានអញ្ជើញឲ្យទៅបោះឆ្នោត ។ អ្នកទាំងនេះត្រូវរើសបន្ថែម ក្រៅអំពីប្រធានាធិបតី អនុប្រធានាធិបតី នូវសមាជិក៣៤រូបសំរាប់សភាជាន់ខ្ពស់ហៅ Sénat ទៀត (គឺជាចំនួនសមាជិក១ភាគ៣រើសរាល់រយៈ ២ ឆ្នាំ ក្នុងចំណោមសមាជិកសរុប១០០នាក់ដែលត្រូវរើសសំរាប់រយៈ៦ឆ្នាំ) នូវសមាជិកចំនួន៤៣៥រូបសំរាប់សភាតំណាងហៅ la chambre des Représentants (គឺចំនួនទាំងអស់) ដែលត្រូវជាប់សំរាប់រយៈពេល២ឆ្នាំ នូវចំនួនពាក់កណ្តាលចំនួនសរុបនៃអ្នកគ្រប់គ្រងហៅ Gouverneurs (គឺចំនួនអ្នកគ្រប់គ្រង២៥រូបនៃចំនួន៥០នាក់គ្រប់គ្រងរដ្ឋផ្សេងៗ ដែលរើសសំរាប់រយៈពេល២ឬ៤ឆ្នាំ) ហើយនឹងនូវចំនួនអ្នកតំណាង អ្នករដ្ឋការ ចៅក្រម ។ល។ ប្រមាណរាប់ម៉ឺនរូបដែលធ្វើការនៅក្នុងស្រុក (ដូចជានៅនារដ្ឋនានា នៅខេត្ត, ស្រុក,ឃុំ) ។

គឺខែវិច្ឆិកាក្រោយនេះហើយ ដែលជាពេលវេលាមួយដែលជីវភាពនយោបាយនៃ ស.រ.អា. ត្រូវទទួលទម្ងន់ការមួយនឹងពណ៌សម្បុរមួយផ្សេងឡើង ។ គេច្រើននិយាយថា គឺប្រទេសទាំងមូលដែលធ្លាក់ក្នុងពាកល្បែងឃោសនារបស់ទិនានុប្បវត្តិ

# ប្រធានាធិបតីនៅសហរដ្ឋអាមេរិក

សារពត៌មាន វិទ្យុទូរទស្សន៍ វិទ្យុ បច្ចុប្បន្នភាពនៃភាពយន្ត សៀវភៅ ការផ្សាយគ្រប់បែបយ៉ាង ការប្រជុំសាធារណៈ និងការប្រជុំខាងនយោបាយនានា ៗ គឺជា សម័យកាលមួយដែលបង្កើតនូវគលឧបាយ នូវរឿងរ៉ាវដ៏លាយឡំទៅនឹងសិល្បៈឬបញ្ហានយោបាយ ។

គឺប្រមាណជាជាងមួយឆ្នាំហើយ ដែលអំណាចនៃការឃោសនាបោះឆ្នោតរបស់អាមេរិកាំងត្រូវប្រកាសផ្សាយដោយពពួកអ្នកបច្ចេកទេស ព្រមទាំងអ្នកវិជ្ជាជីវៈដែលឋិតនៅក្នុងផ្នែកឧស្សាហកម្ម និងហិរញ្ញវត្ថុជាប់មុខ ។

តើការបោះឆ្នោតតាំងប្រធានាធិបតីប្រព្រឹត្តទៅបែបណា ? តើការរៀបចំបោះឆ្នោតនេះប្រព្រឹត្តទៅយ៉ាងណា ? ▣

## វិធីបោះឆ្នោតរបស់អាមេរិក

ផ្ទុយអំពីប្រទេសអឺរ៉ុបខាងលិចនិងប្រទេសក្នុងសហពន្ធអង់គ្លេស (Dominions britanniques) ដែលបានយករបៀបបោះឆ្នោតតាមបែបអង់គ្លេសនោះ ស.រ.អា. បានបង្កើតវិធីបោះឆ្នោតតាមវិធីប្រធានាធិបតីគឺថា រដ្ឋាភិបាលឋិតនៅក្នុងកណ្ដាប់ដៃរបស់ប្រធានាធិបតីដែលជ្រើសរើសដោយការបោះឆ្នោតសាកល ឯរដ្ឋមន្ត្រីដែលពួកអាមេរិកាំងហៅថា ,,រដ្ឋលេខាធិការ Secrétaire,, គឺជាអ្នកជំនួយកិច្ចការរដ្ឋរបស់ប្រធានាធិបតី អាចផ្លាស់ប្ដូរបានតាមចិត្តប្រធានាធិបតី ប៉ុន្តែមិនទទួលខុសត្រូវនៅចំពោះមុខរដ្ឋសភា (le Congrès) ទេ ។

តំណែងរបស់ប្រធានាធិបតីមានប្រយោជន៍សំខាន់ណាស់ ។ ដូចនេះហើយបានជាគណបក្សទាំងពីរ (បក្សសាធារណរដ្ឋ និងប្រជាធិបតេយ្យ) គោះប្រជុំសមាជិកទាំងអស់របស់ខ្លួនតាំងពីរយៈពេលមួយយ៉ាងយូរមុនបោះឆ្នោត ដើម្បីរៀបចំការបោះឆ្នោតដើម្បីស្ទៀបស្ទង់មតិសាធារណជនអាមេរិក ជ្រើសរើសបេក្ខជនណាដែលគាំពារ

ប្រយោជន៍ ពណ៌សំបុររបស់បក្សព្រមទាំងប្រឹងប្រែងប្រយុទ្ធគ្នាយ៉ាងខ្លាំងក្លា ដើម្បីយក ‹‹សេតវិមាន›› ។ បក្សនិមួយៗរកគ្រប់មធ្យោបាយដើម្បីប្រឡូកក្នុងការឃោសនាបោះឆ្នោត។ តាមធម្មតា ក្នុងការប្រឡូកយកចាញ់ឈ្នះបែបនេះ មានតែអ្នកមានៗព្រមទាំងវណ្ណៈខ្ពង់ខ្ពស់ផ្ដាច់មុខប៉ុណ្ណោះទេដែលជាអ្នកចូលរួមក្នុងការប្រយុទ្ធនេះ ។

របៀបបោះឆ្នោតដែលពិសេសនៅ ស.រ.អា. មានទំរង់ស្មុគស្មាញបន្តិច ។ ដោយហេតុថាប្រធានាធិបតី ព្រមទាំងអនុប្រធានាធិបតីត្រូវជ្រើសរើសតាមការបោះឆ្នោតសកលនោះ ការជ្រើសរើសអ្នកទាំងពីររូបនេះមានសារៈសំខាន់ខ្លាំងណាស់ ។ ការបោះឆ្នោតរើសប្រធានាធិបតីប្រព្រឹត្តទៅជាច្រើនរយៈ ។ ដំបូងឡើងគេរើសបេក្ខជន ។ គេបញ្ជូលប្រតិភូនៃបក្សនិមួយៗនៅក្នុងរដ្ឋ ។ ការបញ្ជូលឈ្មោះនេះអាចធ្វើតាមការជ្រើសរើសនៅក្នុងគណៈកម្មាធិការប្រចាំតំបន់របស់បក្សក៏បាន ឬជួនកាលសំរាំងតាម‹‹ការបោះឆ្នោតបឋម›› (les élections primaires) រកបេក្ខជនប្រធានាធិបតីក៏បាន។ ប្រតិភូទាំងឡាយដែលរើសសំរាំងបានក្នុងបក្សនិមួយៗនេះប្រជុំគ្នាជាបន្ទាប់មកតាម ‹‹ អនុសញ្ញាជាតិ ›› (la convention notionale) របស់បក្ស ។ នេះគឺជាសន្និបាតនៃប្រតិភូ ដែលជ្រើសរើសបេក្ខជនជាផ្លូវការនៃបក្សនិមួយៗ សំរាប់ឋានៈប្រធានាធិបតីនិងឋានៈអនុប្រធានាធិបតី ។ ជាចុងបង្ហើយ គឺការចាប់ឃោសនាបោះឆ្នោះពេញលេញនៃបេក្ខជនប្រធានាធិបតីរបស់បក្សទាំងពីរ (គឺបក្សប្រជាធិបតេយ្យនិងបក្សសាធារណរដ្ឋ) ។

## ‹‹ការបោះឆ្នោតបឋម›› រើសបេក្ខជនប្រធានាធិបតី

ការបោះឆ្នោតបឋមរើសបេក្ខជនប្រធានាធិបតី គឺជាការដែលសមាជិកបក្សនិមួយៗមានឈ្មោះក្នុងបញ្ជីអាចបោះឆ្នោតដោយផ្ទាល់រើសបេក្ខជន ។ ចំណែកឯអ្នកបោះឆ្នោតដែលគ្មានបក្ស (ម្នាក់ក្នុងចំណោម៥រូប) មិនត្រូវចូលរួមក្នុងការរើសនេះឡើយ។

ប៉ុន្តែរដ្ឋទាំងអស់មិនមែនថាត្រូវតែអនុម័តតាមរបៀបជ្រើសរើសនេះទេ។ មានតែចំនួនរដ្ឋមួយភាគបីប៉ុណ្ណោះទេក្នុងរដ្ឋទាំង៥០ ដែលបានប្រើវិធី‹‹រើសបេក្ខជនបឋម››

នេះ ។ ចំណែករដ្ឋឯទៀតៗ ប្រគល់ឲ្យនៃបក្ស (គណៈកម្មាធិការប្រចាំតំបន់)រើសប្រតិភូរបស់បក្សរៀងៗ ខ្លួនតែម្ដង ។

បេក្ខជន ប្រធានាធិបតីត្រូវឋិតនៅក្នុងវិធីបោះឆ្នោតបឋម ដឹកក្នុងគោលបំណងឲ្យប្រតិភូនៃរដ្ឋនិមួយៗជួយទ្រទ្រង់ខ្លួន ឬក្នុងគោលបំណងឲ្យគេផ្ដុំឆ្នោតមកលើឈ្មោះខ្លួនក្នុងការបោះឆ្នោតតាមរដ្ឋ ។ ធ្វើបែបនេះគឺដើម្បីបន្ថែមលទ្ធភាពជោគជ័យរបស់ខ្លួននៅពេលជ្រើសរើសសំរេចនៃបក្សតាមរយៈអនុសញ្ញាជាតិ ។

គឺដូចនេះហើយបានជាបេក្ខជនចំបងៗនៅក្នុងបក្សប្រកួតប្រជែងប្រយុទ្ធគ្នាក្នុងការបោះឆ្នោតបឋមដើម្បីបេក្ខជនប្រធានាធិបតី ។ ប៉ុន្តែក្នុងករណីខ្លះ បេក្ខជនប្រធានាធិបតីដែលឈ្នះឆ្នោតក្នុងមួយដំណាក់នៃការជ្រើសរើសបឋមហើយ ជួនកាលប្រែជាពុំជាប់ឆ្នោតអំពីបក្សទៅវិញ មកពីប្រតិភូនៃរដ្ឋឯទៀតៗពុំបានបោះឆ្នោតឲ្យអ្នកនោះនៅក្នុងអនុសញ្ញាជាតិនៃបក្ស ។

ការបោះឆ្នោតបឋមរើសបេក្ខជនប្រធានាធិបតីនេះបានប្រើជាលើកដំបូងនៅក្នុងឆ្នាំ ១៩០៥ ក្នុងរដ្ឋ ‹‹វីសកុងស៊ីន Wisconsin ›› ដែលមានបំណងនឹងពង្រីកវិធីជ្រើសតាំងបេក្ខជនក្នុងការបោះឆ្នោតទូទៅ ។ កាលពីដើមគណៈបក្សបំពេញមុខងារជាផ្លូវការនឹងជាសាធារណៈក្នុងការចាត់តាំងប្រធានាធិបតីដែលពួកអាមេរិកាំងហៅថា « ការតែងតាំង les nominations » ។ បេក្ខភាពពុំមែនធ្វើឡើងដោយសេរីទេ ។ មានតែគណៈបក្សជាផ្លូវការទេទើបអាចដាក់បេក្ខជនឲ្យឈរបាន ហើយគណៈបក្សនេះទៀតត្រូវអនុវត្តបេក្ខភាពទៅតាមច្បាប់ប្រាកដប្រជាផង ។

គណៈកម្មាធិការនៃបក្ស ជាអ្នកទទួលមុខងារខាងចាត់តាំងបេក្ខជនសំរាប់តំណែងប្រធានាធិបតី ដែលគេហៅថា ‹‹គុកុស caucus ›› តមកវិធីបុរាណនេះត្រូវបានផ្លាស់តាមបែបថ្មីហៅថា ‹‹អនុសញ្ញា Convention ›› វិញ ។ អនុសញ្ញាគឺជាសន្និបាតនៃប្រតិភូរបស់សង្កាត់ក្នុងក្រុង ឬ របស់តំបន់នៃស្រុក ។ ប៉ុន្តែដោយបក្សមានសិទ្ធិពេញទីចំពោះ

ការជ្រើសរើសប្រតិភូនេះ វិធីតាមអនុសញ្ញាក៏ហាក់ដូចជាពុំបាននាំមកនូវការពេញចិត្តឡើយ ។ ជាលំដាប់មកទៀត វិធីក្រោយនេះត្រូវផ្លាស់ជា "ការបោះឆ្នោតបឋម" ឬហៅថា "បឋមប្រធានាធិបតី" វិញ ។ ឯវិធីនេះទៀតក៏ពុំបានទទួលអនុវត្តប្រើនៅក្នុងរដ្ឋទាំងអស់ដែរ ។

ការបោះឆ្នោតបឋមសំរាប់បេក្ខភាពប្រធានាធិបតីប្រព្រឹត្តទៅតាមថ្នាក់រដ្ឋ ក្រោមកិច្ចពិនិត្យរបស់រដ្ឋការនៃរដ្ឋនិមួយៗនោះ ។ ដូច្នេះហើយរបៀបបោះឆ្នោតនេះពុំគោរពទៅតាមច្បាប់របស់សហពន្ធរដ្ឋទាល់តែសោះ គឺស្រេចនៅលើរបៀបចាត់រៀបចំនៃរដ្ឋនិមួយៗ ។ មានតែអនុសញ្ញាជាតិនៃបក្សប៉ុណ្ណោះទេ ដែលអាចតាំងបេក្ខជនរបស់ខ្លួននៅតំណែងប្រធានាធិបតី ថ្នាក់សហពន្ធនៃរដ្ឋបាន ។

## អនុសញ្ញាជាតិនៃបក្ស

អនុសញ្ញាជាតិគឺជាសន្និបាតប្រជុំអស់ទាំងប្រតិភូពីគ្រប់រដ្ឋរបស់បក្សនិមួយៗ ផ្ទុយអំពីការបោះឆ្នោតផ្ដាច់ព្រាត់រើសប្រធានាធិបតីដែលធ្វើសំរាប់សហពន្ធនៃរដ្ឋទាំងមូល អនុសញ្ញាជាតិធ្វើឡើងស្រេចតែច្បាប់ទំលាប់នៃបក្សនិមួយៗប៉ុណ្ណោះ ។ ការប្រជុំនេះធ្វើឡើងសំរាប់បញ្ចេញសម្ដែងនូវឆន្ទៈរបស់បក្ស ។

ការរៀបចំអនុសញ្ញាគឺជាការងារនៃគណៈកម្មាធិការជាតិរបស់បក្សដែលមានការប្រជុំបុរសនិងស្ត្រីជាតំណាងរដ្ឋនិមួយៗក្នុងចំណោមរដ្ឋទាំង៥០ នៃស.រ.អា. ។ គឺគណៈកម្មាធិការនេះហើយដែលសំរេចនូវទីកន្លែង នូវកាលបរិច្ឆេទនៃអនុសញ្ញា ហើយដែលសំរេចនូវចំនួនប្រតិភូដែលនឹងតំណាងរដ្ឋនិមួយៗ ដោយយោងទៅលើចំនួនប្រជាជនព្រមទាំងផលប្រយោជន៍នយោបាយនៃរដ្ឋ ។

ប្រតិភូរាប់រយនាក់ដែលមកប្រជុំក្នុងអនុសញ្ញានយោបាយជាតិ នាំគ្នាបោះឆ្នោតសំរេចជាចុងក្រោយបំផុត ដើម្បីជ្រើសតាំងមនុស្សដែលគេជឿជាក់ថានឹងអាចមានជោគជ័យក្នុងប្រធានាធិបតីមែន ។

– បំពោះបក្សសាធារណរដ្ឋ ការតែងតាំងប្រធានាធិបតីក្នុងការបោះឆ្នោតនេះ បានធ្វើរួចហើយក្រោយការប្រជុំលើកទី២៨នៃអនុសញ្ញាជាតិរបស់បក្ស ដែលបើកធ្វើនៅថ្ងៃទី១៣កក្កដា នាទីក្រុង "សន់ហ្វ្រង់ស៊ីស្កូ" ។ លទ្ធផលសំរេចបានទៅអ្នកដៃក្តៅ ឈ្មោះបារ៉ី ហ្គោលវ៉ាទែរ Barry Goldwater ។

– បំណែកឯបក្សប្រជាធិបតេយ្យ ការជ្រើសរើសបានធ្វើនៅថ្ងៃ២៤សីហា នៅ«អាត្លង់ទិច ស៊ីទី Atlantic City» (រដ្ឋញូវ ហ្សឺស៊ី New Jersey) ។ នេះគឺជាអនុសញ្ញាជាតិទី ៣៤ របស់បក្ស ហើយឯលទ្ធផលបានដល់ឈ្មោះ ជន សុន Johnson (ឈ្មោះនេះជាប្រធានាធិបតីសព្វថ្ងៃ) ។

អនុសញ្ញានិមួយៗ ក៏ត្រូវរើសបេក្ខជនសំរាប់អនុប្រធានាធិបតី ព្រមទាំងឲ្យសច្ចានុម័តិលើកម្មវិធីនៃបក្សថែមទៀត (ដូចជាសេចក្តីថ្លែងការទូរគោលការណ៍ ព្រមទាំងគោលសកម្មភាពនយោបាយដែលនឹងយកទៅអនុវត្តនៅពេលឃោសនាបោះឆ្នោត) ។ បន្ទាប់ពីនេះគឺការបើកឃោសនាបោះឆ្នោតដែលបង្កើត «ភ្លៀងផ្គរប្រកាប់ប្រចាក់ដោយគ្នាដូចសត្វនរក» រហូតទៅដល់ថ្ងៃទី ៣ វិច្ឆិកា ។

## ការឃោសនាបោះឆ្នោត

បេក្ខជនប្រធានាធិបតី ក្រោយដែលបានទទួលសច្ចានុមតិដោយអនុសញ្ញាជាតិអំពីបក្សរបស់ខ្លួនរួចហើយ ក៏បានទៅជាអ្នកដឹកនាំអ្នកកាន់ទង់នៃបក្សក្នុងកម្លុងពេលនៃការឃោសនាបោះឆ្នោត ។

ពេលនេះជាពេលដែលបេក្ខជនម្នាក់ៗនៃបក្សទាំងពីរប្រមូលអស់សមត្ថភាពកម្លាំងពលំរបស់ខ្លួនដើម្បីប្រើនូវមធ្យោបាយធំៗក្នុងការឃោសនា ការផ្សាយតាមវិទ្យុ តាមកាសែត ធ្វើយ៉ាងណាឲ្យខាងគេបានជោគជ័យក្នុងការប្រជែងប្រណាំងយក "សេត-វិមាន" ។ ចំពោះវិធីបែបនេះ គេប្រមាណឃើញថាទំហំនៃការឃោសនាបោះឆ្នោតរើសប្រធានាធិបតីអាមេរិកាំងគេចំណាយប្រាក់អស់ប៉ុន្មានទៅ ។ ដើម្បីនឹងមានលុយធ្វើបែបនេះកើត ទាល់តែមនុស្សនោះជាអ្នកមានអំណាច មានធនធានធំសំបើម នឹងអ្នកមានជាប់មុខក្នុងវិស័យឧស្សាហកម្ម ឬហិរញ្ញវត្ថុ ។

អានក្នុងសារព័ត៌មាន « ឡាដេប៉ែស »

ប្រវត្តិវិទ្យា

# កាលបរិច្ឆេទសំខាន់ៗនៃប្រវត្តិសាស្ត្រឥណ្ឌូណេស៊ី ចាប់តាំងពីឆ្នាំ១៩៤៥ មក

○ ១៧ សីហា ១៩៤៥

ការប្រកាសឯករាជ្យ

○ ២៥ មីនា ១៩៤៧

កិច្ចព្រមព្រៀងនៅឡាំងគ្ហាស្ហាទី ដើម្បីបង្កើត (សហរដ្ឋឥណ្ឌូណេស៊ី)

○ កក្កដា ១៩៤៧

ប្រតិបត្តិការដំបូងនៃក្រុមនគរបាលជាតិហុល្លង់

○ ១៧ មករា ១៩៤៨

កិច្ចព្រមព្រៀងនៅរេនវីល

○ កញ្ញា ១៩៤៨

ការបះបោរនៃពួកកុម្មុយនីស្តនៅម៉ាឌីយូន

○ ធ្នូ ១៩៤៨ ប្រតិបត្តិការទី ២ នៃក្រុមនគរបាល

○ សីហា—វិច្ឆិកា ១៩៤៩

សន្និសីទតុមូលនៅឡាហេ

○ ២៩ ធ្នូ ១៩៤៩ ការផ្ទេរអធិបតេយ្យភាពពីប្រទេសហុល្លង់ទៅសហរដ្ឋឥណ្ឌូណេស៊ី

○ សីហា ១៩៥០

សហរដ្ឋឥណ្ឌូណេស៊ីឯកភាពក្លាយទៅជាសាធារណរដ្ឋឥណ្ឌូណេស៊ី

○ ១៨–២៤ មេសា ១៩៥៥

សន្និសីទនៅបានឌុង

○ ២១ កុម្ភៈ ១៩៥៧

លោកសឹការណូ សូត្រសន្ទរកថាដើម្បីផ្សាយគំនិតរបស់លោក ការចាប់ផ្ដើមបះបោរនៅកោះស៊ុយម៉ាត្រា និងសេឡេប ។

○ ៥ កក្កដា ១៩៥៩

ការរំលាយសភាបញ្ញត្តច្បាប់ ហើយនឹងការត្រឡប់មកប្រើរដ្ឋធម្មនុញ្ញអាស្រ័យប្រធានាធិបតីឆ្នាំ១៩៤៥ វិញ ។

○ ១៧ សីហា ១៩៥៩

លោកសឹការណូ សូត្រសន្ទរកថាដើម្បីផ្សាយនិវេទនបណ្ណនយោបាយ (ម៉ានីប៉ូល) នៃប្រទេសឥណ្ឌូណេស៊ី ។

○ មីនា ១៩៦០

សភាថ្មី ‘‘គ្ហោតុងគ្រ្ហោស្ហុង,,

○ ទី ១ ឧសភា ១៩៦៣

អ៊ីរីយ៉ង់បារ៉ាតត្រឡប់មកឋិតនៅក្រោមការត្រួតត្រារបស់ជាតិឥណ្ឌូណេស៊ី ។

○ មករា ១៩៦៣

ប្រទេសឥណ្ឌូណេស៊ី យកអាកប្បកិរិយាប្រឆាំងនឹងការបង្កើតសហភាពម៉ាឡេស៊ីយ៉ា ហើយនឹងផ្ដើមនយោបាយប្រឆាំងនឹងសហភាពនេះ ។

ទើបនឹងផ្សាយចេញ

## មូលភាពនៃការបង្កើតពាក្យថ្មី

## PRINCIPES DE CREATION DES MOTS NOUVEAUX

ដោយលោក កេង វ៉ាន់សាក់

សៀវភៅបែបសិក្សាកថា (livre d'étude) និងសក្ខាហកថា (essai) នេះ ជាសៀវភៅដែលទើបនឹងចេញជាលើកដំបូងនៅប្រទេសយើងក្នុងវិស័យអក្សរសាស្ត្រជាតិ បន្ទាប់ពីសៀវភៅ «សាកល្បងពិនិត្យភាសាខ្មែរដោយរកហេតុផល» (La Langue cambodgienne-Un essai d'étude raisonnée) របស់លោក អៀវ កើស មក (គ.ស. ១៩៤៧)។

សៀវភៅនេះឋិតនៅក្នុងប្រភេទសៀវភៅទស្សនវិជ្ជា ព្រោះថា ការសិក្សាពន្យល់ដោយមតិ និង ទស្សនៈតែងតែធ្វើឲ្យអត្ថបទសិក្សាកថា និងសក្ខាហកថា ប្រកបទៅដោយលក្ខណៈនៃទស្សនវិជ្ជា ជាដរាប ។

ក្នុងសៀវភៅនេះ អ្នកនិពន្ធបានខិតខំស្រាវជ្រាវពិនិត្យពិចារណាពិភាក្សាតាមវិទ្យាវិធីនូវ«ការបង្កើតពាក្យថ្មី» ដើម្បីធ្វើឲ្យពាក្យថ្មីទាំងឡាយឋិតនៅក្នុងឯកភាព ងាយអាន ងាយចាំ ងាយប្រើ ហើយមានតម្លៃទៅចំពោះជនជាតិទាំងមូលផង ។

យើងយល់ថា ស្នាដៃនេះនឹងផ្តល់នូវវិភាគទានមួយយ៉ាងធំដល់ភាសានិងវប្បធម៌ខ្មែរយើង ហើយយើងជឿថា ស្នាដៃនេះមុខតែនឹងបានទទួលបដិសណ្ឋារកិច្ចដ៏កក់ក្តៅពីបណ្តាខេមរជនអ្នកស្នេហាអក្សរសាស្ត្រ-ភាសាជាតិយើង ដែលតែងតែស្រេកឃ្លាននូវវិជ្ជាពន្យល់អំពីអក្សរសាស្ត្រយើងជាមិនខាន ។

សៀវភៅប្រកបទៅដោយសារៈសំខាន់នេះ បានមហាវិទ្យាល័យអក្សរសាស្ត្រនិងមនុស្សវិជ្ជានៃរាជសាកលវិទ្យាល័យយើង យល់ព្រមទទួលហើយ ។

៦៦២ ទំព័រ - មានលក់នៅគ្រប់បណ្ណាគារ ។

# ដំណឹងមិត្តយើង

នៅក្នុងបវេសនកាលនេះ មិត្តយើងបានទទួលការផ្លាស់ប្តូរជាច្រើន ៗ តាមដំណឹងខ្លះៗដែលយើងបានទទួលមានដូចតទៅនេះ (សូមមិត្តអភ័យទោសដោយយើងមិនអាចចុះឈ្មោះទាំងអស់គ្នាបាន) :

មិត្ត កុយ ជួន ពីវិទ្យា ព្រះស៊ីហនុ ទៅអនុវិ មង្គលបូរី, បាត់ដំបង

– យ៉ាង ជួន – – – សម្តេចឧបយុវរាជ, សៀមរាប

– អ៊ឹង គឹមសេង – – – ព្រះរាជបូ.ឯករាជ្យ, ស៊ួនគ្រេន

– តាន់ ទ្រី – – – រស្មី សោភ័ណ, កំពង់ធំ

– (កញ្ញា) សាន សំអាត – – – កំពង់ឆ្នាំង, បឋមសិក្សា

– (អ្នកស្រី) អៀង សាវី នាយកវិទ្យាខ្មែរ-អង់គ្លេស ទៅ បង្រៀនវិទ្យាល័យស៊ីសុវត្ថិ

– ព្រុំ សង្ហារ សិក្សាធិការ – – សាលាជាតិខាងសិល្បៈនិងមុខរបរ

– កែប ផន – វិទ្យា ឥន្ទ្រទេវី ជានាយការ. មន្ទីរអប់រំជាតិ

– សុន សោម – – ចៅពញាយ៉ាត ទៅ បង្រៀន វិទ្យា ស៊ីសុវត្ថិ

– ង៉ូវ វ៉ា ចាន់ហ្វានអនុវិ តាំងគោក ជានាយកវិទ្យា ឥន្ទ្រទេវី

– ឈ គឹមហុង នាយកវិទ្យា ស៊ីសុវត្ថិ ជានាយកវិទ្យា សង្គមរាស្ត្រនិយម

– ជា ឃួនហួង ពី – – ទៅជាសិក្សាធិការ –

– អ៊ឹន រ៉ុម សិក្សាធិការវិទ្យា ស.រ.និយម ជានាយកវិទ្យាចៅពញាយ៉ាត

– មាស ឌឹម នាយកវិទ្យា ព្រះស៊ីហនុ ជានាយកវិទ្យា ស៊ីសុវត្ថិ

– កៅ លន់ សាស្ត្រា.វិទ្យា.ដ.គ ជានាយកសិក្សានៃវិទ្យាស្ថានជាតិគរុកោស

– ហ៊ូ ប៊ុនបៃ ពីអនុវិទ្យា.បច្ចេក.កំពង់ចាម មកវិទ្យាល័យ ចៅពញាយ៉ាត

មិត្ត(អ្នកស្រី)ហ៊ួ ប៊ុនប៉ៃ ពីវិទ្យាល័យ ព្រះស៊ីហនុ មកវិទ្យា ទៅពញាយ៉ាត

— ប៉ុល សារ៉េត — — ជាចាងហ្វាងអនុវិ បច្ចេកទេសកំពង់ចាម

— ឆ្វូ វិន ចាងហ្វាង អនុវិ បច្ចេកទេស ទៅបង្រៀនអនុវិទ្យាល័យ ដីហៃ

— ឡុក ប៊ុនហួ ពី — - មក — សាលាជាតិសិ.មុ.របរ

— ចាប់ ញឿង – វិទ្យាល័យ ព្រះមុនីវង្ស — — — —

— ងែត គុណា – ម.អ.គ. កំពង់គន្ធ — — — —

— ស៊ាង ស្រេង ចាងហ្វាងអនុវិ សន្តិភាព — — — —

— ពេជ្រ គឹមផេង — — ស្គន់ — — — —

— ទៀវ សារ៉ន — — រស្មីសោភ័ណ ជាចាងហ្វាង អនុវិទ្យាល័យស្គន់

— អ៊ុល បុន្ថ ពីមន្ទីរចាត់ការសិល្បៈ ជានាករង

— គឹម សុនទ្រិញ – វិទ្យា ព្រះមុនីវង្ស មកបង្រៀន វិទ្យា ស៊ីសុវត្ថិ

— ស្វូរ វិន — — ព្រះសុរិយាវង្សទី២ - — —

— ជាវ ជិនបាណា — សាលាជាតិសិ.មុ.របរ — — —

— ម៉ក់ ភឿន — — — — —

— ជី មី — — — — —

— ឃន់ ហ៊ឹម — មន្ទីរអប់រំជាតិ — — ខ្មែរ-អង់គ្លេស

— គង់ អ៊ុន — — ជាសិក្សាធិការ —

— ស ហៃសែម - — — — — ស.រ.និយម

— ជឹម ស៊ុនលី – អនុវិ ព្រះសោទា ទៅបង្រៀនអនុវិល័យ ត្រាំកក់, តាកែវ

— ម៉ៅ សុវណ្ណ និស្សិត បរិញ្ញាបត្រសិក្សាខាងវិទ្យា គណិតវិទ្យា ទៅបង្រៀន វិទ្យាល័យ ព្រះស៊ីហនុ

មិត្ត បន្ទុ អ៊ុល ពីអនុវិ ព្រះគន្ធបុប្ផា មក បង្រៀនវិជ្ជា.ជគ.គរុកោសល្យ

— ម៉េង ស៊ុនហុង — ព្រះកៅឌិន មក — វិទ្យា ត.ខ្មៅ, កណ្ដាល

—(អ្នកស្រី) អ៊ិន វ៉ុន — អាំបយុត ទៅ — ព្រះមុនីវង្ស

— ជា ប៉េង — ចំបក់ ជា ចាងហ្វាង អនុវិ ស្អាង, កណ្ដាល

— យស់ ឆិល ចាងហ្វាងអនុវិ ព្រៃដើមថ្នឹង — — ស្វាយជ្រុំ,ស្វាយរៀង

— ម៉ៅ យ៉ាត ពីវិទ្យា ព្រះសុរិយោវង្ស — — រមាសហែក, —

— វ៉ា ផុន — អនុវិ ព្រះរ.បូ.ឯកពង្ស — — ព្រះរ.បូ.ឯកពង្ស,ស្ទឹងត្រែង

— ព្រំ ព្រិល និស្សិតសាស្ត្រាចារ្យ ទៅ — — ទឹកឃ្លាំង, កណ្ដាល

— អេង គីមឈិន — — — — រស្មីសោភ័ណ,កំពង់ធំ

— គីម ស៊ីយ៉ុង ពីវិទ្យា ព្រះយុគន្ធរ — — — តាំងគោក, កំពង់ធំ

— យស់ វ៉ន នាយកវិទ្យាព្រះឧទេយ្យ — — — អាំបយុត,បាត់ដំបង

— មិញ សាម៉ែល ចាងហ្វាងអនុវិអាំបយុត — — - សន្តិភាព, កំពង់ស្ពឺ

— ស្លុក ប៊ន នាយកវិទ្យា ព្រះសុរិយាវ័ន្តទី ២ — នាយកវិទ្យា ព្រះសីហនុ

— វ៉ាន់ បាន ពី — — — នាយកវិទ្យា ព្រះសុរិយាវ័ន្ត

— ម៉ែន សោមជា — ព្រះសីហនុ — — ចាងហ្វាង អនុវិ ពាមជីកង កំពង់ចាម

— ទៀវ សាវ៉ន ចាងហ្វាងអនុវិ ព្រះសោភ័ណ — - ស្គន់ —

— ប៉ូប សេង ពីវិទ្យា ព្រះអង្គឌួង — — ព្រៃដើមថ្នឹង,ព្រៃវែង

— តោ ឈន់ — — — ពាមរ —

— ម៉ក់ ប៊ុប សិក្សាធិការ វិទ្យា ព្រះសុរិយាវ.ទី២ — — ពួក,សៀមរាប

— ឈឹម សំណាង — — ព្រះឧទេយ្យ — — នាយវិទ្យា ព្រះឧទេយ្យ

— ស៊ុន សុមុទ្រ ពីអនុវិ គិរីវង្ស — ចាងហ្វាងអនុវិ គិរីវង្ស,តាកែវ

មិត្ត ហាប់ ស៊ុប ពីអនុវិ ឆ្លូង ទៅជាចាងហ្វាងអនុវិឆ្លូង,ក្រចេះ

– លា គីមសេង ពីវិទ្យា ព្រះមុនីវង្ស មកបង្រៀនវិជ្ជា.ជ.គរុកោសល្យ

– ស៊ិន អ៊ួន – អនុវិ តានី ទៅជាចាងហ្វាង អនុវិគងពិសី,កំពង់ស្ពឺ

– ជ័យ ភឿន – វិទ្យា ព្រះរាជសម្ភារ – សិក្សាធិការ

– សឿ ក្លូ – – ព្រះទទេយ្យ – –

– ម៉ម ឈឹមហ៊ុយ ចាងហ្វាងអនុវិ គីរីវង្ស – ចាងហ្វាងអនុវិ ដំពូវ័ន,កណ្ដាល

– ឌួ តង់ងួន – ព្រះស.បូ.ឯករាជ្យជាតិ – – ព្រែកអញ្ចាញ,កណ្ដាល

– គង់ សុគន្ធ ពីអនុវិ កោះធំ មកបង្រៀនអនុវិ ដំពូវ័ន

★

មិត្ត ខឹម គ្រាន និស្សិត-សាស្ត្រាចារ្យ ផ្នែកខ្មែរឆ្នាំទី ២ ទើបនឹងបានបាត់បង់បិតារបស់ខ្លួន (លោកអ៊ុំ ខឹម ម៉) កាលពីថ្ងៃ ១៣ តុលា ១៩៦៤ ដោយរោគាពាធ ។ មិត្តរួមថ្នាក់អង្គាសប្រាក់គ្នាបាន ៨៩០ រៀល ជូនមិត្តខឹម គ្រាណ ដើម្បីជាសញ្ញានៃសាមគ្គីភាពផងនឹងដើម្បីសម្រាលទុក្ខរបស់មិត្តផង ។

★

ក្នុងវិស្សមកាលនេះ ក្នុងឱកាសដែល មិត្តអ៊ី សឿង បានទទួលទានដំណេកពេទ្យ សមាជិកគណៈកម្មាធិការនាយកយើង បាន ទៅសាកសួរនៅថ្ងៃ១៦ សីហា ១៩៦៤ ។

★

មិត្ត ថាច់ ចន្ទី នឹងនាង អ៊ី វ៉ែតង់ ទើបនឹងបានរៀបអាពាហ៍ពិពាហ៍ កាលពីថ្ងៃ៩

## ការតែងតាំងថ្មី

លោក ឌួង សារិន អធិការមធ្យមសិក្សាខាងភាសា (ថែមលើតំណែងចាស់)

– ខ្វាន់ ស៊ីផាន់ អធិការមធ្យមសិក្សាខាងភាសា

– ប៉ោង គីមក្វាន អធិការមធ្យមសិក្សា ខាងវិទ្យាសាស្ត្រ

– កែវ ថែម នាយករងមធ្យមសិក្សា

– ថាវ គន្ធ នាយករង ឧត្ដមសិក្សា

– យឿន ណាកស៊ុស នាយកវិទ្យាល័យ ខ្មែរ-អង់គ្លេស

– ទេស សារាវុធ នាយកវិទ្យាល័យព្រះយុគន្ធរ

វិច្ឆិកា ១៩៦៤ នៅភោជនីយដ្ឋាន ថៃសាន ។ អាពាហ៍ពិពាហ៍មង្គលបានប្រព្រឹត្តទៅក្នុងបរិយាកាសយ៉ាងរីករាយ ។

ចំពោះគូសង្សារថ្មីនេះ យើងសូមប្រសិទ្ធជូននូវពរសព្ទសាធុការសព្វបែបយ៉ាងដើម្បីសុភមង្គល ។

## ▣ ក្លូនសៀវភៅពណ៌ក្លូឡាប

ទំព័រកូនសៀវភៅពណ៌កូឡាបរបស់យើងនៅលេខនេះប្រសិនបើពេញ នោះគឺពេញទៅដោយរលកនៃកំណើតរបស់ទារក - ទារិកានៃមិត្តយើងខាងវិទ្យាស្ថានជាតិគរុកោសល្យហ្នឹងឯងហើយ ។ តាមពិត ដំណឹងជាច្រើនបានហូរគគុកមកដល់ទីស្នាក់ការយើង ជាសញ្ញានៃសុភមង្គលរបស់មិត្តយើង ។

នៅមន្ទីរសំភព «មិត្តភាពខ្មែរ-សូវៀត» មិត្ត ស៊ិន សុង មិស្សិត-សាស្ត្រាចារ្យ (និ·សា) បានកូនស្រីមួយទៀតហើយ ।

ចំណែកឯនៅមន្ទីរសំពល«ប៉ុប្បាក្លូង»វិញ នោះគឺជាក្បួនដង្ហែមួយយ៉ាងសុទ្ធសាធតែម្តង। មិត្ត សោម សារិទ្ធ (និ·សា) កូនប្រុស មិត្ត ម៉ែន ហ៊ុល (និ-សា) កូនប្រុស មិត្តទេព ឈន (និ·សា) កូនប្រុស មិត្តតៃ ប៊ុទគីម (មន្ទីរអប់រំជាតិ) កូនប្រុស ,

នៅមន្ទីរពេទ្យ«សុខា» មិត្ត គយ សារុន (និ-សា) បានកូនស្រីមួយទៀត ។ ចំណែកឯមិត្ត រ៉ា ជ្រាន នឹង យិទ គីមគេក (និ-សា) ក៏សុទ្ធតែបានឃើញគ្រួសាររបស់ខ្លួនកើនចំនួនម្នាក់ៗ ទៀតដែរ (ប្រុស)। ហើយមិត្តម្នាក់ដែលបានកូនស្រីក្នុង «សម័យ» នេះ គឺមិត្ត កង សារ៉ន (និ·សា) ។

ចំពោះមិត្តទាំង ៩ នាក់នេះ យើងសូមប្រសិទ្ធនូវពរសព្ទសាធុការសុភមង្គលក្នុងគ្រួសារ ហើយសូមប្រសិទ្ធឲ្យទារក-ទារិកាទាំង ៩ មានព្រលឹងមាំមួនតរៀងទៅ ។







មានសេចក្ដីរីករាយនឹងចុះថ្លៃ
ជូនយ៉ាងពេញចិត្ត ចំពោះមិត្តដែលបាន
បង្ហាញប័ណ្ណសមាជិកនៅពេលទិញខោអាវ
នៅហាងនេះ ។


---


មានលក់នៅបណ្ណាគារ សារវត្ថីតូប លេខ ៩២ផ្សារចាស់ ភ្នំពេញ

—បញ្ញាសីលា លេខ ១៣៤ R វិថីព្រះសីហនុ ភ្នំពេញ

១ លេខ ២១ រៀល